# សិទ្ធិមនុស្ស និងពន្ធនាគារកម្ពុជា:

# ស្ថានភាពពន្ធនាគារឆ្នាំ ២០០៤

របាយការណ៍អង្គការលីកាដូ (សង្ខេប)

ខែ ធ្នូ ឆ្នាំ ២០០៥

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

**លីកាដូ** គឺជាអង្គការសិទ្ធិមនុស្សក្នុងស្រុកមួយនៅកម្ពុជា ។ ចាប់តាំងពីអង្គការលីកាដូត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារសិទ្ធិមនុស្សនៅកម្ពុជា និងដើម្បីលើកកំពស់ការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិខាងផ្នែកនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការស្ថាបនាលើសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ**នៅតែបន្តជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងជាអ្នកឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានានៃការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងការិយាល័យនៅទូទាំង ១២ ខេត្តផ្សេងទៀត។

**លីកាដូនៅតែបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៦ របស់ខ្លួន ដូចខាងក្រោម:**

- **ការិយាល័យអប់រំសិទ្ធិមនុស្ស** គឺជាការិយាល័យដែលបើកវគ្គហ្វឹកហ្វឺនសិទ្ធិមនុស្សដល់ក្រុមគោលដៅនានា ដូចជាមន្ត្រីរាជការ សិស្ស និស្សិត ព្រះសង្ឃ ព្រមទាំងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្សដល់សាធារណៈជននានាថែមទៀតផង ។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះនានាក្នុងដំណើរការណ៍ពាក់ព័ន្ធខាងផ្លូវច្បាប់។ បុគ្គលិកដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវ ក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយអោយពិរុទ្ធជននានា ទទួលបាននូវតំណាងផ្នែកច្បាប់។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារ នៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះក៏បានផ្តល់សេវាវេជ្ជ-សាស្ត្រ និងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **គម្រោងប្រឆាំងទារុណ្ណកម្ម** ជាការិយាល័យផ្តល់សេវាស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណ្ណកម្ម និងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណ្ណកម្ម។

- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី និងធ្វើការតស៊ូមតិ ដើម្បីអោយមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។

## ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:


លោកស្រី **វេជ្ជបណ្ឌិត ពុង ឈីវកេក** ប្រធានអង្គការលីកាដូ

អាស័យដ្ឋានៈ អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
អាគារលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤ ៩០១

ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល: contact@licadho.org

គេហទំព័រ: http://www.licadho.org

# មាតិកា

**របាយការណ៍សង្ខេប ---------- ១**

**១. បុព្វកថា ---------- ៧**

**២. បញ្ហាថ្មីៗក្នុងឆ្នាំ ២០០៤ ---------- ១០**

ក. វិធីចម្លាស់ថ្មីក្នុងការឃុំឃាំង_ការបម្រើសហគមន៍ ---------- ១០

ខ. ការរត់ចេញពីពន្ធនាគារ ---------- ១២

គ. ការស្លាប់ក្នុងពន្ធនាគារ ---------- ១៣

**៣. ចំនួនអ្នកទោសក្នុងពន្ធនាគារ ---------- ១៦**

ក. ការកើនឡើងនូវចំនួនអ្នកទោស ---------- ១៦

ខ.លទ្ធភាពពន្ធនាគារ និងភាពចង្អៀត ---------- ១៧

**៤. ក្រុមជនងាយនឹងរងគ្រោះក្នុងពន្ធនាគារ ---------- ២១**

ក. ស្ត្រី ---------- ២១

ខ. កុមារគ្មានទោស_កម្មវិធីផ្តល់ជំនួយដល់ស្ត្រីមានផ្ទៃពោះនិងកុមារក្នុង
ពន្ធនាគារ_ ---------- ២៣

គ. អ្នកទោសអនីតិជន និងយុត្តិធម៌កុមារ ---------- ២៥

ឃ. ពិរុទ្ធជនជាប់ឃុំបណ្តោះអាសន្ន ---------- ៣០

**៥. អំពើពុករលួយ ---------- ៣៣**

**៦. អំពើទារុណកម្ម ---------- ៣៧**

ក. ទារុណកម្មក្នុងកន្លែងឃុំឃាំងនគរបាល ---------- ៣៩

ខ. ទារុណកម្មក្នុងពន្ធនាគារ ---------- ៤០

# របាយការណ៍សង្ខេប

ចាប់តាំងពីឆ្នាំ ១៩៩៧ អង្គការលីកាដូ បានចេញរបាយការណ៍នានាស្តីពីសិទ្ធិមនុស្សនៅក្នុងពន្ធនាគារកម្ពុជា ដោយបានលើកឡើងនូវកង្វល់អំពីសិទ្ធិមនុស្សធ្ងន់ធ្ងរជាច្រើន និងបានស្នើឡើងនូវវិធីមួយចំនួន ដើម្បីផ្លាស់ប្តូរថែមទៀត។ ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យមួយ **លីកាដូ** មានគោលបំណងសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ឃ្លាំមើលពន្ធនាគារកម្ពុជា និងសិទ្ធិរបស់ទណ្ឌិត-ពិរុទ្ធជន
- ផ្សព្វផ្សាយព័ត៌មាននានាឥតលំអៀង និងមានគុណភាពខ្ពស់
- ធ្វើការបញ្ចុះបញ្ចូលដើម្បីអោយមានការកែទម្រង់ជាវិជ្ជមាន

នេះជាការសង្ឃឹមរបស់យើងដែលរបាយការណ៍នេះនឹងត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល និងមន្ត្រីពន្ធនាគារ អ្នកតស៊ូមតិ អ្នកស្រាវជ្រាវ ផ្នែកឃោសនា អង្គការផ្តល់មូលនិធិ ក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈច្បាប់នានាដើម្បីជាឧបករណ៍ដោះស្រាយបញ្ហានានាដែលកើតមានឡើង ដើម្បីកែលំអស្ថានភាពពន្ធនាគារ និងលើកកំពស់សិទ្ធិរបស់ពិរុទ្ធជន-ទណ្ឌិត ។

នៅឆ្នាំ ២០០៤ **លីកាដូ** បានជួបប្រទះបញ្ហាមួយចំនួនក្នុងពន្ធនាគារកម្ពុជា ដូចខាងក្រោមៈ

## បញ្ហាថ្មីៗក្នុងឆ្នាំ ២០០៤

### វិធីថ្មីក្នុងការផ្តន្ទាទោសៈ

វិធីថ្មីក្នុងការផ្តន្ទាទោស គឺការបម្រើសហគមន៍។ វិធីនេះគួរតែត្រូវបានយកមកប្រើជំនួសការដាក់ទណ្ឌកម្ម ផាកពិន័យ ឬ ការឃុំឃាំង ពីព្រោះវាមានលក្ខណៈមនុស្សធម៌ជាង ក្នុងការអនុវត្តការដាក់ទោសទៅលើទណ្ឌិត។

### អនុសាសន៍

- កម្ពុជាគួរតែធ្វើច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់ខ្លួនដោយបញ្ចូលការបម្រើសហគមន៍នៅក្នុងច្បាប់នោះ។
- កំណត់ចំនួនទណ្ឌិតក្នុងការអនុវត្តការបម្រើសហគមន៍

- លើកកំពស់សេវាកម្មសហគមន៍ដោយចាត់ទុកជាវិធីចម្បាស់ដែលផ្តល់ប្រយោជន៍ដល់យុវជនប្រព្រឹត្តបទល្មើសនានា។

## ការរត់គេចពីពន្ធនាគារ

ក្នុងឆ្នាំ ២០០៤ **លីកាដូ**បានកត់សម្គាល់ឃើញមានអ្នករត់ចេញពីពន្ធនាគារ ២១ នាក់។ ការដាក់អ្នកទោសលើសចំណុះ ចង្អៀតពេក ជាកត្តានាំអោយអ្នកទោសបង្ខំចិត្តរត់គេចចេញពីពន្ធនាគារ ហើយការធ្វេសប្រហែសរបស់អ្នកយាមក៏ជាការផ្តល់ឱកាសអោយអ្នកទោសរត់ពីពន្ធនាគារផងដែរ។

## អនុសាសន៍

- កុំដាក់អ្នកទោសច្រើនលើសចំណុះ ដើម្បីកាត់បន្ថយកត្តាដែលជម្រុញអោយអ្នកទោសចង់រត់គេចចេញពីពន្ធនាគារ
- ធ្វើការហ្វឹកហ្វឺនជំនាញទៅដល់អ្នកយាមពន្ធនាគារអោយបានប្រសើរជាងមុន ហើយការធ្វើបែបនេះ ជាការជួយកាត់បន្ថយការចង់រត់គេចរបស់អ្នកទោស

## ការស្លាប់នៅក្នុងបន្ទប់ឃុំឃាំង

ក្នុងឆ្នាំ ២០០៤ **លីកាដូ** បានកត់ត្រាអ្នកស្លាប់ក្នុងពន្ធនាគារ ៥៨ នាក់ ដែលភាគច្រើនស្លាប់ដោយសារជម្ងឺ។ ករណីខ្លះ គឺជាការស្លាប់ដោយសារជម្ងឺដែលមានស្រាប់តាំងពីនៅក្រៅពន្ធនាគារ ហើយជម្ងឺនោះកាន់តែធ្ងន់ធ្ងរឡើងពេលចូលមកដល់ក្នុងពន្ធនាគារ ហើយករណីស្លាប់ខ្លះទៀតបណ្តាលមកពីជម្ងឺដែលកើតមានក្នុងកំឡុងពេលជាប់ពន្ធនាគារ ។

## អនុសាសន៍

- ចាត់វិធានការទប់ទល់នឹងការស្លាប់ក្នុងពន្ធនាគារ
- បង្កើនការយកចិត្តទុកដាក់ក្នុងការព្យាបាលដល់អ្នកទោសដែលមានជម្ងឺ
- ផ្តល់ម្ហូបអាហារដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ដល់អ្នកទោស ដើម្បីជៀសវាងពីការខ្វះសារជាតិ និងដើម្បីកាត់បន្ថយកំរិតជំងឺក្នុងខ្លួនអ្នកទោស។

## ចំនួនអ្នកទោសក្នុងពន្ធនាគារ

ក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ចំនួនអ្នកទោសក្នុងពន្ធនាគារនានា មានការកើនឡើងយ៉ាងខ្លាំង ហើយពុំមានការចាត់វិធានការណាមួយ ដើម្បីកាត់បន្ថយការកើនឡើងនេះឡើយ ។

### អនុសាសន៍

- ពង្រីកពន្ធនាគារនៅខេត្តបាត់ដំបង និងកំពង់ធំ
- ទំហំពន្ធនាគារក្នុងខេត្តនីមួយៗ គួរធ្វើអោយសមាមាត្រទៅនឹងចំនួនប្រជាពលរដ្ឋរបស់ខេត្ត
- សម្របសម្រួលជាមួយសង្គមស៊ីវិល

## ក្រុមជនដែលងាយនឹងរងគ្រោះ

### ស្ត្រីក្នុងពន្ធនាគារ

ស្ត្រី គឺជាជនទទន់ខ្សោយងាយនឹងរងគ្រោះនូវការបង្ខិតបង្ខំ ដូចជា ការគំរាមកំហែងពីការ-ប្រើអំពើហិង្សា ការរំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាស់ជាដើម នៅពេលដែលគាត់ត្រូវបានគេយកទៅឃុំឃាំងនៅក្នុងបន្ទប់ពន្ធនាគារដែលមានបុរសនៅជុំវិញ ។

### អនុសាសន៍

- ត្រូវដាក់ស្ត្រីនៅក្នុងបន្ទប់ឃុំឃាំងដែលមានសុវត្ថិភាពដោយធ្វើយ៉ាងណាអោយពួកគាត់នៅឆ្ងាយពីទណ្ឌិតបុរស
- ត្រូវធ្វើគោលនយោបាយ ដើម្បីការពារស្ត្រីជាប់ឃុំឃាំងអោយគេចផុតពីការបៀតបៀន-កេរ្តិ៍ខ្មាស់ និងការរំលោភសេពសន្ថវៈ
- ផ្តល់សេវាកម្មសុខាភិបាលដល់ស្ត្រីមានផ្ទៃពោះដែលចង់សម្រាលកូនក្នុងពន្ធនាគារ ឬអនុញ្ញាតអោយពួកគាត់អាចសម្រាលកូននៅមន្ទីរពេទ្យដោយមានការថែទាំជាបន្តបន្ទាប់

## កុមារគ្មានទោសក្នុងពន្ធនាគារ

ច្បាប់អនុញ្ញាតអោយកុមារដែលមានអាយុក្រោម ៦ ឆ្នាំ រស់នៅជាមួយឳពុកម្តាយក្នុងពន្ធនាគារ។ កុមារទាំងនោះច្រើនតែខ្វះសិទ្ធិ ដូចជា សិទ្ធិក្នុងការអប់រំ សុខភាព និងម្ហូបអាហារជាដើម។

## អនុសាសន៍

- គួរដាក់កុមារ និងម្តាយរបស់កុមារដាច់ដោយឡែកពីអ្នកទោសបុរស
- គួរផ្តល់ការយកចិត្តទុកដាក់ពិសេសដល់កុមារដើម្បីអោយមានការលូតលាស់ខាងរូបរាងកាយ និងប្រាជ្ញាស្មារតី
- គួរបង្កើតអោយមានកម្មវិធីអប់រំ និងថែទាំកុមារ
- គួរផ្តល់មូលនិធិដល់កុមារ និងម្តាយក្នុងពន្ធនាគារអោយបានសមរម្យ

## អនីតិជនក្នុងពន្ធនាគារ

ក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្ននេះ ពុំទាន់បានកំណត់អាយុអប្បបរមាដែលអាចទទួលខុសត្រូវក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនៅឡើយទេ។ អនីតិជនត្រូវបានគេដាក់ឃុំឃាំងជាមួយមនុស្សចាស់ដែលជាអ្នកទទួលរងនូវការធ្វើទារុណ្ឌកម្មនៅក្នុងទីឃុំឃាំងនគរបាល និងពន្ធនាគារដោយពុំមានការប្រើប្រាស់វិធីចម្លាស់ណាក្រៅពីការធ្វើបែបនេះក្នុងការដាក់ទណ្ឌកម្មដល់អនីតិជនឡើយ។

## អនុសាសន៍

- បន្ថែមមាត្រាមួយនៅក្នុងច្បាប់ព្រហ្មទណ្ឌដែលមានចែងថា កុមារទាំងឡាយណាដែលមានអាយុក្រោម ១៣ ឆ្នាំមិនត្រូវយកទៅដាក់ឃុំឃាំង ឬផ្តន្ទាទោសតាមច្បាប់ឡើយ។
- ដាក់កុមារ និងមនុស្សចាស់អោយនៅដាច់ពីគ្នា
- នាយកដ្ឋានពន្ធនាគារគួរផ្តល់ម្ហូបអាហារបន្ថែម ការថែទាំសុខភាព និងផ្តល់ការអប់រំដល់អនីតិជនដែលកំពុងមានការលូតលាស់ផ្នែករាងកាយ និងប្រាជ្ញាស្មារតី
- បង្កើតអោយមានប្រព័ន្ធយុត្តិធម៌យុវជនសម្រាប់កុមារដែលមានបញ្ហាពាក់ព័ន្ធនឹងច្បាប់ ។

## ពិរុទ្ធជន

កន្លងមក មានការកើនឡើងនូវចំនួនពិរុទ្ធជនយ៉ាងច្រើន (រួមទាំងពិរុទ្ធជនមួយចំនួនត្រូវបានគេឃុំលើសពីនីតិវិធី ៦ ខែ) ក្នុងពន្ធនាគារក្នុងឆ្នាំ ២០០៤។

## អនុសាសន៍

- រដ្ឋាភិបាលគួរផ្តល់ថវិកាដល់ថ្នាំពន្ធនាគារអោយបានគ្រប់គ្រាន់ដើម្បីដឹកជញ្ជូនពិរុទ្ធជនទៅតុលាការ
- ចាត់តាំងចៅក្រមថ្មី ហើយផ្តល់មធ្យោបាយអោយបានច្រើនសមរម្យដើម្បីស៊ើបអង្កេតអោយមានប្រសិទ្ធិភាព។
- កែលំអ ឬ ពង្រីកអាគារឃុំឃាំងដើម្បីអោយមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់ពិរុទ្ធជនអោយដាច់ពីទណ្ឌិត ។

## អំពើពុករលួយ

ពុករលួយ ជាអំពើដែលប៉ះពាល់ដល់ជីវភាពពន្ធនាគារយ៉ាងច្រើន ដូចជា ការទទួលម្ហូប-អាហារបន្ថែមនិងទឹកស្អាត ការសួរសុខទុក្ខពីសំណាក់គ្រួសារ ការចេញហាត់ប្រាណក្រៅបន្ទប់ឃុំឃាំង និងការដឹកជញ្ជូនទៅសវនាការនៅតុលាការជាដើម ។

## អនុសាសន៍

- ត្រូវផ្តល់មូលនិធិបន្ថែមដល់នាយកដ្ឋានពន្ធនាគារ ដើម្បីធានាការផ្គត់ផ្គង់តម្រូវការជាមូល-ដ្ឋានរបស់អ្នកទោស ។
- ធ្វើយ៉ាងណាបើកថវិកាអោយពន្ធនាគារអោយបានទៀងទាត់តាមពេលវេលាកំណត់
- ធ្វើសវនកម្ម (ត្រួតពិនិត្យ) ថវិកាពន្ធនាគារជាប្រចាំ
- ត្រួតពិនិត្យមន្ត្រីរាជការពន្ធនាគារ
- បញ្ឈប់ការទារសំណូកដោយថ្នាំពន្ធនាគារជាថ្នូរនឹងការអនុញ្ញាតអោយអ្នកទោសចេញហាត់ប្រាណក្រៅបន្ទប់ឃុំឃាំង និងការទារថ្លៃដឹកជញ្ជូនពីពន្ធនាគារទៅតុលាការ ។

# ទារុណកម្ម

ទារុណកម្ម គឺជាបញ្ហាមួយដែលនៅតែកើតមានឥតឈប់ឈរមកលើអ្នកទោសកម្ពុជា ហើយក៏ជាអំពើមួយក្នុងចំណោមអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនានាដែលអ្នកស្រាវជ្រាវ**លីកាដូ** បានសង្កេតឃើញនៅតាមពន្ធនាគារនានា។

## អនុសាសន៍

- គួរផ្តល់ការហ្វឹកហ្វឺនដែលមានលក្ខណៈកាន់តែល្អប្រសើរទៅដល់បុគ្គលិកពន្ធនាគារ ដើម្បីអោយបុគ្គលិកទាំងនោះត្រូវតែគោរពបទដ្ឋានអប្បបរមាក្នុងការអនុវត្តទៅលើអ្នកទោសដូច-ដែលមានចែងនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ។
- លប់បំបាត់ការប្រើប្រាស់អ្នកទោសអោយដាក់ពិន័យទណ្ឌកម្មលើអ្នកទោសដូចគ្នា
- ពេលបញ្ជូនពិរុទ្ធជនមកដល់ពន្ធនាគារ ត្រូវពិនិត្យ និងរាយការណ៍អំពីរបួសរបស់ពិរុទ្ធជន
- ត្រូវអនុញ្ញាតអោយបុគ្គលិកអង្គការសិទ្ធិមនុស្សសម្ភាសន៍អ្នកទោសដោយពុំមានឆ្មាំនៅក្បែរ
- ឆ្មាំនិងអ្នកទោសទាំងឡាយណាដែលប្រព្រឹត្តអំពើទារុណកម្ម ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

# ១. បុព្វកថា

របាយការណ៍ឆ្នាំ ២០០៤ របស់**លីកាដូ**នេះ គឺជារបាយការណ៍ថ្មីដែលកែសម្រួល និងដកស្រង់ចេញពីរបាយការណ៍ស្តីពីស្ថានភាពពន្ធនាគារឆ្នាំ ២០០២-២០០៣ ។

ចាប់តាំងពី**លីកាដូ** បានចាប់ផ្តើមកម្មវិធីពន្ធនាគាររបស់ខ្លួននៅឆ្នាំ ១៩៩៦ មក ការចូលពិនិត្យមើលពន្ធនាគារត្រូវបានធ្វើឡើងជាប្រចាំដើម្បីឃ្លាំមើល លើកកំពស់ និងការពារសិទ្ធិជនជាប់ចោទ និងពិរុទ្ធជនទាំងឡាយដែលត្រូវបានកាត់ទោស។

## វិធីសាស្រ្ត

ព័ត៌មាននៅក្នុងរបាយការណ៍នេះ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមរវាងកម្មវិធីពន្ធនាគារ និងការិយាល័យពេទ្យនៃអង្គការលីកាដូ។ ក្នុងឆ្នាំ ២០០៤ **លីកាដូ** បានធ្វើបទសម្ភាសន៍ជាមួយអ្នកទោសសរុបចំនួន ២.៨៩២ នាក់ ។ នៅក្នុងឆ្នាំនោះដែរអ្នកស្រាវជ្រាវពន្ធនាគារ**លីកាដូ** បានចូលពិនិត្យពន្ធនាគារចំនួន ១៨[1] កន្លែងក្នុងចំណោមពន្ធនាគារកម្ពុជាសរុប ២៦ កន្លែង[2] ដោយចូល ៤ ដង ក្នុងមួយខែក្នុងពន្ធនាគារនីមួយៗ ។

*តារាងទី ១: ចំនួនទណ្ឌិត និងពិរុទ្ធជនដែល**លីកាដូ**បានសម្ភាសន៍ក្នុងឆ្នាំ ២០០៤ ក្នុងពន្ធនាគារចំនួន ១៨*

| ខែ | បុរស | | ស្រ្តី | | សរុប |
|---|---|---|---|---|---|
| | ពិរុទ្ធជន | ទណ្ឌិត | ពិរុទ្ធជន | ទណ្ឌិត | |
| មករា | ១៤៨ | ៧០ | ១៨ | ៤ | ២៤០ |
| កុម្ភៈ | ១៩៧ | ៥៧ | ១៨ | ០ | ២៧២ |
| មិនា | ២០២ | ៥៣ | ១០ | ១ | ២៦៦ |
| មេសា | ១៤០ | ៥៣ | ១២ | ០ | ២០៥ |

[1] នគរបាលយុត្តិធម៌ ( PJ ) មណ្ឌលកែប្រែទី១ មណ្ឌលកែប្រែទី២ ត្រពាំងថ្លុង (T5) ទួលស្លែង តាខ្មៅ ក្រុងព្រះសីហនុ កំពង់ស្ពឺ កំពត កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង និង កោះកុង។

[2] **លីកាដូ** ឃ្លាំមើលពន្ធនាគារណាដែលនៅជិតការិយាល័យកណ្តាលភ្នំពេញ និងការិយាល័យទាំង ១២ ខេត្តតែប៉ុណ្ណោះ ។

| | | | | | |
|---|---|---|---|---|---|
| ឧសភា | ២០៩ | ៤៧ | ១៥ | ១ | ២៧២ |
| មិថុនា | ១៧៩ | ៤៧ | ២១ | ៤ | ២៥១ |
| កក្កដា | ១៣៧ | ៩១ | ៦ | ៦ | ២៤០ |
| សីហា | ១៤៣ | ៦៩ | ១៨ | ៦ | ២៣៦ |
| កញ្ញា | ១៦០ | ៥២ | ១៤ | ១ | ២២៧ |
| តុលា | ១៤២ | ៤២ | ១៣ | ០ | ១៩៧ |
| វិច្ឆិកា | ១២៨ | ៥១ | ២២ | ៧ | ២០៨ |
| ធ្នូ | ១៩៩ | ៥២ | ២៧ | ០ | ២៧៨ |
| សរុប | ១៩៨៤ | ៦៨៤ | ១៩៤ | ៣០ | ២៨៩២ |

គួរកត់សំគាល់ថា របាយការណ៍នេះ ជាការបង្ហាញនូវទិដ្ឋភាពតូចមួយនៃស្ថានភាព និងអំពើហិង្សារំលោភសិទ្ធិមនុស្សនៅក្នុងពន្ធនាគារកម្ពុជាតែប៉ុណ្ណោះ ចំពោះហេតុផលដូចមានពន្យល់នៅខាងក្រោមនេះ។

រាល់ការចុះពិនិត្យក្នុងពន្ធនាគារ អ្នកស្រាវជ្រាវពន្ធនាគារ**លីកាដូ** តែងតែត្រូវបានគេចាត់អោយធ្វើការរៀបចំទុកជាមុន។ ការអនុវត្តបែបនេះ ជាទូទៅជួយអោយមានកិច្ចសហប្រតិបត្តិការពីសំណាក់មន្ត្រីពន្ធនាគារ។ ប៉ុន្តែការផ្តល់ដំណឹងជាមុនបែបនេះ ក៏អាចជាការផ្តល់ឱកាសអោយមន្ត្រីពន្ធនាគារមានពេលបិទបាំងនូវអំពើហិង្សារបស់ខ្លួនទៅលើអ្នកទោសមួយចំនួនផងដែរ។ លើសពីនេះទៅទៀត អាជ្ញាធរពន្ធនាគារមួយចំនួនបានកំរិតសកម្មភាពការចូលពិនិត្យពន្ធនាគាររបស់អ្នកស្រាវជ្រាវ។ និន្នាការនៃការកំរិតបែបនេះ នឹងមានរាយការណ៍ លំអិតជាងនេះនៅក្នុងរបាយការណ៍ឆ្នាំ ២០០៥។

អ្នកស្រាវជ្រាវពន្ធនាគារ បានជ្រើសរើសអ្នកទោសដើម្បីសម្ភាសន៍ដោយប្រើបញ្ជីឈ្មោះដែលមាននៅតាមពន្ធនាគារនីមួយៗ ប៉ុន្តែការសម្ភាសន៍កម្រធ្វើដោយសម្ងាត់ណាស់។ អ្នកស្រាវជ្រាវពន្ធនាគារបានប្រើប្រាស់កំរងសំណួរតាមបទដ្ឋានមួយប្រភេទដើម្បីសម្ភាសន៍អ្នកទោស។ កំរងសំណួរនោះ បានផ្តល់លទ្ធភាពអោយអ្នកទោសរាយការណ៍អំពីបញ្ហាទាំងឡាយដែលកើតមាននៅក្នុងពន្ធនាគារ ហើយតាមរយៈការរាយការណ៍របស់អ្នកទោសនេះហើយ ដែលធ្វើអោយអង្គការលីកាដូអាចឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៅក្នុងពន្ធនាគារបាន។

## បញ្ជីសំណួរត្រូវបានបែងចែកជា ៥ ផ្នែកដូចខាងក្រោម:

១. ***សេចក្តីផ្តើម:*** តើគេដាក់អ្នកនៅក្នុងពន្ធនាគារណា កាលបរិច្ឆេទសម្ភាសន៍ និងកាលបរិច្ឆេទដោះលែង ។

២. ***ប្រវត្តិរូប:*** ព័ត៌មានទូទៅទាក់ទងនឹងប្រវត្តិរូប រួមមាន ជំនាញ ភេទ ទំងន់ ឈ្មោះឪពុក-ម្តាយ និងចំនួនកូនរស់នៅក្នុងពន្ធនាគារជាមួយ។

៣. ***ការចាប់ខ្លួន:*** ទីកន្លែងចាប់ខ្លួន ការពិពណ៌នាអំពីការចាប់ខ្លួន ព័ត៌មានលំអិតរបស់អ្នកទោស តើនគរបាលមានប្រាប់អោយសូកប៉ាន់ឬទេ និងបទល្មើសដែលត្រូវបានចោទប្រកាន់ ។

៤. ***ការឃុំឃាំង:*** កាលបរិច្ឆេទឃុំឃាំង តើមានការធ្វើបាបឬទេ ហើយតើអ្នកមានមេធាវីឬទេ?

៥. ***សវនាការ:*** កាលបរិច្ឆេទសវនាការ តើតុលាការមានទារលុយឬទេ ការវិនិច្ឆ័យទោស ទោសដែលបានចោទ ការផ្តន្ទាទោស និងឈ្មោះមេធាវី ។

ព័ត៌មានដែលទទួលបានពីការសម្ភាសន៍ ត្រូវបានបញ្ចូលគ្នាទាំងអស់ដើម្បីធ្វើការវិភាគទំហំនៃការរំលោភសិទ្ធិមនុស្សក្នុងពន្ធនាគារអោយបានត្រឹមត្រូវថាតើមានការពាក់ព័ន្ធនឹងបញ្ហាសុខភាព ទារុណ្ឌកម្ម បន្ទប់ចង្អៀតខ្លាំង ការសូកប៉ាន់ ការរកមេធាវី ការឃុំឃាំងលើសលក្ខខ័ណ្ឌកំណត់ ឬត្រូវបានកំណត់ថ្ងៃសវនាការរួចហើយ ។

អ្នកស្រាវជ្រាវពន្ធនាគារ បានធ្វើសម្ភាសន៍ផ្ទាល់មាត់ដោយប្រើកំរងសំណួរ ហើយកត់ត្រានូវចម្លើយរបស់អ្នកទោសនៅក្នុងទំរង់។ អ្នកទោសអាចមិនហ៊ានឆ្លើយដោយស្មោះត្រង់ប្រាប់អ្នកស្រាវ-ជ្រាវទេ ដោយសារមានអ្នកយាម ឬអ្នកទោសដទៃនៅជិត។ ជាទូទៅអ្នកស្រាវជ្រាវមិនអាចរក្សា ឬធានាអោយមានការសម្ងាត់បានទេចំពោះការសម្ភាសន៍។

ក្នុងករណីមួយចំនួន **លីកាដូ** ក៏បានបន្តការតាមដានដោយសាកសួរអ្នកទោសដែលត្រូវបានដោះលែង ដើម្បីប្រមូលព័ត៌មានបន្ថែមដែលទាក់ទងនឹងស្ថានភាពពន្ធនាគារ។ ការអនុវត្តបែបនេះនៅមិនទាន់បានក្លាយជាវិធីដែលត្រូវបានអនុវត្តជាប្រចាំដោយ**លីកាដូ**នៅឡើយទេ ប៉ុន្តែវានឹងអាចក្លាយជាវិធីមួយដែលនឹងអនុវត្តទៅថ្ងៃអនាគត។ ការសាកសួរព័ត៌មានបន្ថែមនៅក្រៅពន្ធនាគារនេះច្រើនតែធ្វើឡើងនៅពេលដែលអ្នកស្រាវជ្រាវពន្ធនាគារ**លីកាដូ** សង្ស័យថា អតីតអ្នកទោសនោះជាជនរងគ្រោះដោយអំពើទារុណ្ឌកម្ម ឬការរំលោភបំពាន ប៉ុន្តែគាត់មិនហ៊ាននិយាយក្នុងពន្ធនាគារ។

ជាចុងក្រោយ ចំពោះរបាយការណ៍នេះ **លីកាដូ** ក៏បានប្រមូលព័ត៌មានដែលទទួលបានតាមរយៈការសម្ភាសន៍ម្តងម្កាលជាមួយនឹងនាយកពន្ធនាគារ ឬសម្ភាសន៍ថ្នាំ មេធាវី និងគ្រួសាររបស់អ្នកទោសជាដើម ។

# ២. បញ្ហាថ្មីក្នុងឆ្នាំ ២០០៤

## ក. វិធីចម្លាស់ថ្មីក្នុងការឃុំឃាំង -ការបម្រើសហគមន៍

ក្នុងកំឡុងពេលសរសេររបាយការណ៍នេះ ការអនុវត្តបម្រើសហគមន៍មិនទាន់មាននៅក្នុងច្បាប់កម្ពុជានៅឡើយទេ។ ប៉ុន្តែ ចលនាបានចាប់ផ្តើមតាក់តែងមាត្រាស្តីអំពីការបម្រើសហគមន៍ត្រូវបានរៀបចំឡើងចូលទៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី។[៣] ការព្រាង និងការអនុវត្តច្បាប់នេះ អាចជាផលប្រយោជន៍ ដោយវាជាទម្រង់ ឬ វិធីដាក់ទោសថ្មីមួយ ចំពោះអ្នកទោសមួយចំនួន។ ជាងនេះទៅទៀត បទបញ្ញត្តិ ជាបទដ្ឋានអប្បបរមាចំពោះវិធានការដាក់ទោសមិនឃុំឃាំងរបស់អង្គការសហប្រជាជាតិ (មាត្រា៥) បានស្នើអោយរដ្ឋទាំងឡាយបង្កើតការដាក់ទោសដោយមិនឃុំឃាំងក្នុងពន្ធនាគារនៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួនដើម្បីកាត់បន្ថយការប្រើប្រាស់ការឃុំឃាំង និងជួយអោយមានការស្តារលទ្ធភាពឡើងវិញ។[៤]

កន្លងមកមានសេចក្តីព្រាងក្រមព្រហ្មទណ្ឌកម្ពុជាជាច្រើនដែលមានបំណងចង់ដាក់ការបម្រើសហគមន៍ចូលទៅក្នុងសេចក្តីព្រាងទាំងនោះ។ មានសេចក្តីព្រាងចុងក្រោយមួយដែលគេបានដាក់ការបម្រើសហគមន៍ដូចជា:[៥]

**១.** រយៈពេលនៃការបម្រើសហគមន៍ គឺចន្លោះពី ៣០ ទៅ ២០០ ម៉ោង ក្នុងមួយឆ្នាំ (មាត្រា ប.១២១៣-១) អនីតិជនក៏ត្រូវបម្រើសហគមន៍ដែរជំនួសការឃុំឃាំង ប៉ុន្តែត្រូវកំណត់ត្រឹមតែ ១០០ ម៉ោងប៉ុណ្ណោះ (ប.១២៦១-៣) ។

---

[3] Michel Bonnieu, គម្រោងក្រមព្រហ្មទណ្ឌថ្មី Comente et Compare (ហ្វូណន ភ្នំពេញ) ២០០៥។

[4] បទបញ្ញត្តិជាបទដ្ឋានអប្បបរមាចំពោះវិធានការមិនឃុំឃាំងរបស់អង្គការសហប្រជាជាតិ (បទបញ្ញត្តិក្រុងតូក្យូ) អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិតាមសេចក្តីសម្រេចលេខ ៤៥/១១០ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩០ ។

[5] Bonnieu, supra note 3.

២. នៅពេលដែលជនជាប់ចោទណាម្នាក់ត្រូវទទួលទោសឃុំឃាំងក្នុងពន្ធនាគាររហូត ដល់ ៣ឆ្នាំ នោះតុលាការអាចតម្រូវអោយគាត់បម្រើសហគមន៍បាន។ គោលបំណង នៃការដាក់អោយបម្រើសហគមន៍ គឺជាការងារឥតបានកម្រៃ ហើយបានកម្រៃទៅ រដ្ឋ ខេត្ត ក្រុង ស្រុក ឬអាចជានីតិបុគ្គលសាធារណៈ ឬអង្គការមិនមែនរដ្ឋាភិបាល ណាមួយទៅវិញ (ប.១២១៣-១) ។

## ផលប្រយោជន៍នៃការបម្រើសហគមន៍

ការបម្រើសហគមន៍ អាចមានផលប៉ះពាល់ជាវិជ្ជមានទៅលើចំនួនអ្នកទោស។ ទីមួយ គឺវាបានជួយកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ ហើយព្រមទាំងជួយសន្សំថវិកាទៅដល់រាជរដ្ឋាភិបាលដែលត្រូវប្រើសម្រាប់ទុកដាក់ក្នុងការឃុំឃាំងអ្នកទោស។ ទីពីរ គឺទណ្ឌិតទាំងឡាយ បានចូលរួមចំណែកនៅក្នុងសង្គម ហើយអាចធ្វើអោយជំនាញរបស់ពួកគាត់កាន់តែប្រសើរឡើងសម្រាប់ថ្ងៃអនាគតផងដែរ ដូចជា ពួកគាត់អាចក្លាយជាជាងអគ្គីសនី កសិករ ឬជាងឈើជាដើម។ ទីបី គឺកម្មវិធីបម្រើសហគមន៍ ជាការផ្តល់ឱកាសអោយជនល្មើសដែលទើបតែប្រព្រឹត្តលើកទីមួយ និងអនីតិជនដើម្បីកែប្រែគំនិត។ តាមរយៈការផ្តល់ឱកាសអោយពួកគេនៅជាប់ជាមួយសង្គម ជនល្មើសដែលទើបប្រព្រឹត្តលើកទីមួយ និងយុវជនទាំងឡាយ មានឱកាសកែប្រែគំនិត បែរទៅរកការធ្វើការងារ និងបន្តមានទំនាក់ទំនងជាមួយសហគមន៍តាមវិធីជាវិជ្ជមាន ។

## អនុសាសន៍

១. កម្ពុជាត្រូវធ្វើអោយហើយនូវក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរបស់ខ្លួនអោយបានឆាប់ ព្រមទាំងដាក់ការបម្រើសហគមន៍ចូលក្នុងក្រម និងច្បាប់នោះផង។ ការធ្វើបែប-នេះ វាអាចជួយកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារនានា ហើយជាការល្អសម្រាប់យុវជន និងជនល្មើសដែលទើបតែប្រព្រឹត្តលើកទីមួយ។

២. ការបម្រើសហគមន៍ គួរអនុវត្តក្នុងស្ថានភាពកំណត់។ អ្នកទោសទាំងឡាយដែលត្រូវកំណត់អោយបម្រើសហគមន៍ គួរជាអ្នកទោសដែលទើបតែប្រព្រឹត្តលើកទីមួយ ឬមនុស្សទាំងឡាយដែលត្រូវឃុំឃាំងតិចជាង ៣ ឆ្នាំនៅក្នុងពន្ធនាគារ។ អ្នកទោសទាំងនោះត្រូវដាក់អោយរស់នៅទីកន្លែងមួយដែលឥតផ្លាស់ប្តូរហើយការងារបម្រើសហគមន៍ត្រូវធ្វើនៅក្បែរៗកន្លែងរស់នៅនោះ។ ក្នុងករណីដែលទណ្ឌិតណាមួយមិនចូលខ្លួនបម្រើ នោះតុលាការអាចចេញដីកាចាប់ខ្លួន។

៣. ការបម្រើសហគមន៍ គឺជាវិធីល្អចំពោះយុវជនដែលប្រព្រឹត្តល្មើស។ ការកែប្រែ (ដែលខុសពីការឃុំឃាំងក្នុងពន្ធនាគារ) គឺមានភាពប្រសើរដល់ការវិវឌ្ឍន៍ផ្នែកអារម្មណ៍ និងសុវត្ថិភាពចំពោះយុវជន។

## ខ. ការរត់ចេញពីពន្ធនាគារ

**លីកាដូ** បានឃ្លាំមើល និងតាមដានការរត់ចេញពីពន្ធនាគារពីរ-បីដងក្នុងឆ្នាំ ២០០៤។ ក្នុងចំណោមអ្នកទោសដែលរត់គេចទាំង ២៣ នាក់ (បុរស ២១ និង ស្ត្រី ២នាក់) អ្នកទោស ១២ នាក់ត្រូវបានចាប់មកវិញ។ ក្រៅពីការប៉ុនប៉ងចង់បានសេរីភាពនោះ ក៏នៅមានកត្តាមួយចំនួនទៀតដែលជំរុញអោយមានការរត់គេចនេះដែរ កត្តាទាំងនោះរួមមាន ភាពចង្អៀតណែនខ្លាំងពេក អំពើហិង្សាក្នុងចំណោមអ្នកទោសដូចគ្នា មានការវាយដំ ឬដាក់វិន័យជាប្រចាំដោយឆ្មាំពន្ធនាគារ បញ្ហាសុខភាពយ៉ាប់យ៉ឺនខ្លាំងពេក ខ្វះខាតម្ហូបអាហារ ព្រមទាំងមានឱកាស (ដោយឆ្មាំមានការ-ធ្វេសប្រហែស) ជាដើម។

**<u>ករណីសិក្សាទី ១:</u>**

ពិរុទ្ធជនជាស្ត្រីម្នាក់ នៅពន្ធនាគារខេត្តកំពង់ចាម ត្រូវបានចោទពីបទជួញដូរមនុស្ស នាងបានសម្រាលកូន ១ ខែ មុនពេលត្រូវបើកសវនាការ។ នាងមានបញ្ហាសុខភាពជាច្រើន ហើយក៏ត្រូវបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយទុកអោយប្តីនាងជាអ្នកមើលថែទាំ។ ស្រាប់តែស្ត្រីនោះ ក៏រត់គេចពីមន្ទីរពេទ្យបាត់ទៅ។

**<u>ករណីសិក្សាទី ២:</u>**

នៅខេត្តកំពង់ឆ្នាំង អ្នកទោសភេទប្រុសម្នាក់ដែលត្រូវជាប់ឃុំឃាំង ១១ ឆ្នាំ ពីបទប្លន់ និងសម្លាប់ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ដើម្បីព្យាបាលជម្ងឺ។ គាត់ ក៏រត់គេចបាត់។ បុរសនោះរត់គេចក្នុងឆ្នាំទី ៣ នៃការជាប់ឃុំឃាំងរបស់គាត់។

**<u>ករណីសិក្សាទី ៣:</u>**

ពិរុទ្ធជនស្ត្រីម្នាក់នៅពន្ធនាគារខេត្តបាត់ដំបងត្រូវគេនាំយកទៅសវនាការ។ ក្នុងពេលធ្វើសវនាការនាងសន្ទប់នៅមុខចៅក្រម។ ចៅក្រមក៏បានផ្អាកសវនាការ ហើយអោយគេបញ្ជូន

ស្រ្តីនោះទៅមន្ទីរពេទ្យខេត្តបាត់ដំបង ពេលដល់មន្ទីរពេទ្យ សង្ស៊ានាងមកសួរសុខទុក្ខ ហើយនាំនាងរត់គេចបាត់ទាំងអស់គ្នា ។

## អនុសាសន៍

១. ការដាក់អ្នកទោសចង្អៀតខ្លាំងពេកនៅក្នុងបន្ទប់ឃុំឃាំង និងបញ្ហាសុខភាពអាចជាការជំរុញអោយអ្នកទោសរត់គេចខ្លួន។

២. ដើម្បីជៀសវាងការរត់គេចរបស់អ្នកទោស ឆ្មាំពន្ធនាគារ ត្រូវប្រុងប្រយ័ត្នជានិច្ច។

៣. ពេលបញ្ជូនអ្នកទោសទៅមន្ទីរពេទ្យ ត្រូវការពារសន្តិសុខអោយបានហ្មត់ចត់ជាទីបំផុត។

## គ. ការស្លាប់ក្នុងពន្ធនាគារ

ក្នុងឆ្នាំ ២០០៤ មានអ្នកទោស ៥៨ នាក់ បានស្លាប់នៅក្នុងពន្ធនាគារ និងក្នុងមន្ទីរពេទ្យ ហើយអ្នកទោសទាំងនោះសុទ្ធតែជាបុរស។ អ្នកទោសស្លាប់ច្រើនជាងគេ គឺមណ្ឌលកែប្រែទី១ ដែលមានអ្នកស្លាប់សរុបចំនួន ២២ នាក់។ ក្នុងរយៈពេល ២-៣ ឆ្នាំ កន្លងទៅនេះ ចំនួនអ្នកទោសស្លាប់មានការកើនឡើងជាលំដាប់។ ក្នុងឆ្នាំ ២០០២ មានអ្នកទោសស្លាប់ចំនួន ៤៣ នាក់ ហើយឆ្នាំ ២០០៣ មាន ៤៦ នាក់។

*តារាងទី ២: អ្នកទោសស្លាប់ក្នុងពន្ធនាគារ ២០០២ -២០០៤*

| ពន្ធនាគារ | ២០០២ | ២០០៣ | ២០០៤ | សរុប |
|---|---|---|---|---|
| PJ | ០ | ០ | ១ | ១ |
| ម១ | ១៧ | ១៣ | ២២ | ៥២ |
| ម២ | ១ | ៥ | ៣ | ៩ |
| ម៣ (តេ៥) | ០ | ២ | ២ | ៤ |
| ទួលស្លែង | ០ | ០ | ០ | ០ |
| តាខ្មៅ | ១ | ២ | ៣ | ៦ |
| ក្រ.ព្រ.សីហនុ | ៣ | ១ | ១ | ៥ |
| កំពង់ស្ពឺ | ៣ | ២ | ២ | ៧ |
| កំពត | ៣ | ២ | ១ | ៦ |
| កំពង់ឆ្នាំង | ១ | ១ | ២ | ៤ |

| | | | | |
|---|---|---|---|---|
| កំពង់ចាម | ០ | ៣ | ៣ | ៦ |
| កំពង់ធំ | ០ | ៣ | ២ | ៥ |
| កោះកុង | ០ | ២ | ២ | ៤ |
| ពោធិសាត់ | ០ | ១ | ២ | ៤ |
| បាត់ដំបង | ៦ | ៤ | ៦ | ១៦ |
| ប.ន.មានជ័យ | ៣ | ២ | ៣ | ៨ |
| សៀមរាប | ៤ | ២ | ១ | ៧ |
| ស្វាយរៀង | ១ | ១ | ២ | ៤ |
| សរុប | ៤៣ | ៤៦ | ៥៨ | ១៤៧ |

ក្នុងចំណោមអ្នកទោសស្លាប់ ៥៨ នាក់ដែល**លីកាដូ** បានត្រួតពិនិត្យឃ្លាំមើលក្នុងឆ្នាំ ២០០៤ រួមមាន:

- អេដស៍ - លើសឈាម -គ្រុនចាញ់
- ជម្ងឺខ្វះជីវជាតិ - - ជម្ងឺថ្លើម បេ -អត្តឃាត
- ឈឺសួត - គ្រុនពោះវៀន -គ្មានអាហារបរិភោគ
- របេង - ហឺត -រោគរលាកស្រោមខួរ

បុគ្គលិកពេទ្យ**លីកាដូ** ជាទូទៅមិនអាចដឹងច្បាស់បានថាតើជម្ងឺទាំងនោះត្រូវបានឆ្លងតាំងពីនៅក្រៅពន្ធនាគារ ឬឆ្លងក្នុងខណៈចូលមកដល់ពន្ធនាគារនោះទេ។ ប៉ុន្តែគេបានដឹងថាអ្នកទោសភាគច្រើនបានបាត់បង់ទម្ងន់យ៉ាងច្រើនអាស្រ័យដោយការហូបចុកមិនបានគ្រប់គ្រាន់ ដែលជាហេតុធ្វើអោយពួកអ្នកទោសទាំងនោះងាយនឹងទទួលការឆ្លងជម្ងឺបំផុត។

## HIV និង ភាពខ្វះម្ហូបអាហារ

ជម្ងឺអេដស៍ គឺជាមូលហេតុចម្បងមួយដែលបណ្តាលអោយអ្នកទោសស្លាប់ច្រើនជាងគេក្នុងឆ្នាំ ២០០៤ នេះ ដែលមានអ្នកស្លាប់យ៉ាងហោចណាស់ក៏ ១០ នាក់ដែរ។ អ្នកទោសស្លាប់មួយចំនួនផ្សេងទៀត ក៏មានការសង្ស័យថា មានផ្ទុកមេរោគអេដស៍ដែរ ទោះបីជាពុំមានការបង្ហាញរោគសញ្ញាជាផ្លូវការក៏ដោយក៏វាបានបង្ហាញរោគសញ្ញាអេដស៍ខ្លះដូចជា បាត់បង់ការស្រេកឃ្លាន បាត់បង់ទម្ងន់យ៉ាងលឿន ស្លេកស្លាំង រាគរូះ និងសន្លប់បាត់បង់ស្មារតីជាដើម។

# អនុសាសន៍

១. **គួរមានវិធានការការពារជម្ងឺដល់អ្នកទោសទាំងឡាយ។** ច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិមួយចំនួនបានតម្រូវអោយមានការចាត់វិធានការដើម្បីជៀសវាងកុំអោយអ្នកទោសស្លាប់មុនអាយុ។ ចំណុចនេះមានន័យថា ត្រូវផ្តល់ការព្យាបាលជម្ងឺ ម្ហូបអាហារគ្រប់គ្រាន់ ទឹក និងស្ថានភាពរស់នៅប្រកបដោយអនាម័យដល់ពួកអ្នកទោស។

២. **បង្កើនការយកចិត្តទុកដាក់ក្នុងការព្យាបាលដល់អ្នកទោសមានជម្ងឺ។** គួរបង្កើនលទ្ធភាពអោយអ្នកទោសបានព្យាបាលដោយវេជ្ជបណ្ឌិត ព្យាបាលនៅមន្ទីរពេទ្យ និងទទួលបាននូវការព្យាបាលតាមបែបវេជ្ជសាស្ត្រផ្សេងៗទៀតជាដើម។

៣. គួរផ្តល់ម្ហូបអាហារដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ដើម្បីជៀសវាងការខ្វះអាហារចិញ្ចឹម និងជម្ងឺផ្សេងៗនៅក្នុងពន្ធនាគារ។

៤. គួរចាត់ទុកការស្លាប់របស់អ្នកទោសជាករណីសង្ស័យរហូតដល់មានការបញ្ជាក់អោយបានច្បាស់លាស់។

៥. គួរផ្តួចផ្តើមបង្កើតកម្មវិធីមួយដើម្បីអប់រំមន្ត្រី និងបុគ្គលិកសុខាភិបាលពន្ធនាគារ អំពីការធ្វើអន្តរាគមន៍អោយបានទាន់ពេលវេលាចំពោះជម្ងឺផ្សេងៗ ។

# ៣. ចំនួនអ្នកទោសក្នុងពន្ធនាគារ

## ក. ការកើនឡើងនូវចំនួនអ្នកទោស

ចាប់តាំងពីឆ្នាំ១៩៩៦ ចំនួនអ្នកទោសបានកើនឡើងយ៉ាងច្រើន។ តាមការឃ្លាំមើលរបស់ **លីកាដូ** បានអោយដឹងថា ចំនួនអ្នកទោសដែលមានអាយុពេញវ័យ បានកើនឡើងពីរដងចាប់តាំងពីឆ្នាំ១៩៩៨[6] មក ចំណែកឯរាជរដ្ឋាភិបាលវិញ បានចាត់វិធានការណ៍តិចតួចណាស់ ដើម្បីសម្រួលដោះស្រាយដល់ការកើនឡើងនោះ។ កន្លងមកឃើញមានតែនៅខេត្តកណ្តាលប៉ុណ្ណោះដែលកំពុងដំណើរការណ៍កសាងអគារពន្ធនាគារថ្មី។

*តារាងទី ៣: កំណើនចំនួនអ្នកទោសមនុស្សពេញវ័យសរុបក្នុងពន្ធនាគារចំនួន ១៨ កន្លែង ដែលលីកាដូ បានឃ្លាំមើលចាប់តាំងពីឆ្នាំ ១៩៩៨*




## អត្រាកំណើនចំនួនអ្នកទោស

ខណៈដែលចំនួនអ្នកទោសនៅតែបន្តកើនឡើងនោះ អត្រានៃចំនួនអ្នកទោសមានការថយ-ចុះក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ចន្លោះឆ្នាំ ១៩៩៩ និងឆ្នាំ ២០០០ អត្រាកំណើនអ្នកទោស បានកើនឡើង ២១.៤% ហើយចន្លោះឆ្នាំ ២០០៣ និង ២០០៤ អត្រាកំណើននេះនៅត្រឹម ៤.៧% ។

*តារាងទី ៤: អត្រាកំណើនប្រចាំឆ្នាំនៃចំនួនអ្នកទោសឆ្នាំ ១៩៩៨ -២០០៤*

[6] ចំនួនអ្នកទោសក្នុងឆ្នាំ ២០០៤ បានកើនឡើងយ៉ាងខ្លាំងចាប់ពីខែមករា ដែលមានចំនួន ៥.៤៤២ នាក់។ ហើយនេះ គឺជាចំនួនអ្នកទោសបុរសនិងស្ត្រីពេញវ័យដែលមានអាយុលើសពី ១៨ ឆ្នាំប៉ុណ្ណោះ។ យោងតាមស្ថិតិរបស់**លីកាដូ** អនីតិជនមានចំនួន ៣២៨ នាក់ (បុរស និង ស្ត្រី) នៅក្នុងពន្ធនាគារនានានៅខែ ធ្នូ ឆ្នាំ ២០០៤។




*តារាងទី ៥: ស្ថិតិអ្នកទោសឆ្នាំ ២០០៤*

| ចំនួនអ្នកទោសក្នុងខែធ្នូ ឆ្នាំ ២០០៤ | | | |
|---|---|---|---|
| | ពិរុទ្ធជន | ទណ្ឌិត | សរុប |
| បុរស | ១.៧៧៨ | ៣.៨៤៥ | ៥.៦២៣ |
| ស្ត្រី | ១៥០ | ១៩៥ | ៣៤៥ |
| អនីតិជន បុរស | ១៦២ | ១៥៧ | ៣១៩ |
| អនីតិជន ស្ត្រី | ៤ | ៥ | ៩ |

## ខ. លទ្ធភាពពន្ធនាគារ និងភាពចង្អៀត

តាមលទ្ធផលនៃការកើនឡើងនូវចំនួនអ្នកទោស និងការពង្រីកទំហំពន្ធនាគារដ៏តិចតួចនោះ ភាពចង្អៀតណែនខ្លាំង គឺជាបញ្ហាមួយចំពោះនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។ មានពន្ធនា-គារជាច្រើនដែលមានភាពចង្អៀតខ្លាំងលើសលប់ ដែលនាំមកនូវបញ្ហានានាដូចជា ការរត់ចេញពីពន្ធនាគារ អំពើហិង្សារវាងអ្នកទោសដូចគ្នា ការរាលដាលរោគ និងការរង់ចាំថ្ងៃបើកសវនាការយ៉ាងយូរ។

*តារាងទី ៦: ស្ថិតិលទ្ធភាពពន្ធនាគារដែលអាចដាក់អ្នកទោសបាន និងចំនួនអ្នកទោសពិតប្រាកដ*

| លេខ | ពន្ធនាគារ | លទ្ធភាព ពន្ធនាគារ | ចំនួនអ្នកទោស (ចាស់_កុមារ) ក្នុងខែមករា ២០០៤ | ចំនួនអ្នកទោស (ចាស់_កុមារ) ក្នុងខែធ្នូ ២០០៤ | ភាគរយនៃភាពចង្អៀត តួលេខដែលគ្រោងដាក់ និងតួលេខ ខែធ្នូ ២០០៤ | ចំនួន ប្រជាពលរដ្ឋក្នុងខេត្ត[7] |
|---|---|---|---|---|---|---|
| ១ | PJ | ១០០ | ៧៤ | ៧៥ | គ្មាន | ១.១៨៤.៩៤៥ |
| ២ | ម១ | ១.៥០០ | ១.៤៣៧ | ១.៦០៥ | ៧% | ដូចខាងលើ |
| ៣ | ម២ | ៣៥០ | ៣២២ | ៣៦៦ | ៤% | ដូចខាងលើ |
| ៤ | ម៣ | ១.២០០ | ៧៣២ | ៨២៤ | គ្មាន | ដូចខាងលើ |
| ៥ | ទួលស្លែង | ៥ | ២ | ៤ | គ្មាន | ដូចខាងលើ |
| ៦ | តាខ្មៅ | ៣០០ | ៣០១ | ៣១៦ | ៥.៣% | ៧៩០.១៦៨ |
| ៧ | ក្រ.សីហនុ | ១០០ | ១៥១ | ១៨៨ | ៨.៨% | ១៦១.៧៧៩ |
| ៨ | កំពង់ស្ពឺ | ២០០ | ២១១ | ២០៣ | ១.៥% | ៦៨១.៤៥៦ |
| ៩ | កំពត | ១៨០ | ១៥១ | ១៥៦ | គ្មាន | ៥៨៨.៥៨៣ |
| ១០ | កំពង់ឆ្នាំង | ១២០ | ១៤១ | ១៣៦ | ១៣.៣% | ៤២៣.០១៦ |
| ១១ | កំពង់ចាម | ២៥០ | ៣៦៩ | ៣៨៦ | ៥៤.៥% | ១.៨០០.៤៩៩ |
| ១២ | កំពង់ធំ | ៦០ | ១៤២ | ១៤១ | ១៣៥% | ៦៤២.៩៣២ |
| ១៣ | ពោធិសាត់ | ១០០ | ៨៨ | ៧០ | គ្មាន | ៤១៨.៣០៣ |
| ១៤ | បាត់ដំបង | ២០០ | ៥១៧ | ៥៨១ | ១៩០% | ៨៨៩.៥៥៦ |
| ១៥ | ប.ម.ជ័យ | ២០០ | ៣១៥ | ៣៨០ | ៩០% | ៧០៣.៣៥៦ |
| ១៦ | សៀមរាប | ៥៥០ | ៥៣៧ | ៦០៨ | ១០.៥% | ៧៣២.១១១ |
| ១៧ | ស្វាយរៀង | ២០០ | ១៥៣ | ១៦៥ | គ្មាន | ៥៣១.០៧២ |
| ១៨ | កោះកុង | ៨០ | ៧២ | ៩២ | ១៥% | ១៦៤.៧០៧ |

[7] Who's Who នៅកម្ពុជា។ ផ្តោតពិសេសលើរាជវង្សានុវង្ស ២០០៥_២០០៦ ។ MBN International. http://www.cambodia.gov.kh/unisqll/egov/english/oran.admin.html

## ភាពចង្អៀតខ្លាំងនៅពន្ធនាគារបាត់ដំបង និងពន្ធនាគារកំពង់ធំ

ក្នុងឆ្នាំ ២០០៤ ពន្ធនាគារដែលចង្អៀតខ្លាំងជាងគេបំផុត គឺបាត់ដំបង និងកំពង់ធំដែលលើសដល់ទៅ ១៩០% និង ១៣៥% ពីលទ្ធភាពកំណត់ដែលពន្ធនាគារត្រូវដាក់អ្នកទោស។ ក្រៅពីនេះនៅមានពន្ធនាគារមួយចំនួនទៀតដែលលើសចំណុះផងដែរដូចជា បន្ទាយមានជ័យ (៩០%) កំពង់ចាម (៥៤.៥%) កោះកុង (១៥%) និងកំពង់ឆ្នាំង (១៣.៣%)។

## ទំហំឬលទ្ធភាពពន្ធនាគារមិនសមាមាត្រនឹងចំនួនប្រជាពលរដ្ឋក្នុងខេត្ត

បញ្ហាមួយទៀត គឺកំណើនប្រជាពលរដ្ឋនៅក្នុងខេត្តនីមួយៗ នេះមានន័យថាលទ្ធភាពពន្ធនាគារមិនទាន់សមាមាត្រទៅនឹងចំនួនប្រជាពលរដ្ឋនៅក្នុងខេត្តនៅឡើយ។ ឧទាហរណ៍ លទ្ធភាពពន្ធនាគារនៅខេត្តកំពង់ធំដែលអាចដាក់អ្នកទោសបានត្រឹម ៦០ នាក់ប៉ុណ្ណោះ ពីព្រោះពន្ធនាគារនោះ មានទំហំតូចណាស់បើធៀបទៅនឹងចំនួនប្រជាពលរដ្ឋ ៦៤២.៩៣២ នាក់។

ពន្ធនាគារខេត្តសៀមរាបអាចទទួលអ្នកទោសបាន ៥៥០ នាក់ ហើយចំនួនប្រជាពលរដ្ឋខេត្តមានត្រឹម ៧៣២.១១១ នាក់។ ដូច្នេះពន្ធនាគារខេត្តសៀមរាប មានទំហំធំជាងពន្ធនាគារខេត្តបាត់ដំបងដែលមានប្រជាពលរដ្ឋ ៨៨៩.៥៥៦ នាក់ ហើយក៏ធំជាងបន្ទាយមានជ័យដែលមានប្រជាពលរដ្ឋ ៧០៣.៣៥៦ នាក់ផងដែរ។ ពន្ធនាគារនៅក្នុងខេត្តបាត់ដំបង និងបន្ទាយមានជ័យ អាចដាក់អ្នកទោសបានត្រឹមតែ ២០០ នាក់ប៉ុណ្ណោះ។ បាត់ដំបង គឺជាខេត្តធំទី២នៅកម្ពុជា តែពន្ធនាគារនៅខេត្តនេះមានភាពចង្អៀតខ្លាំងជាងគេបំផុត។ ដូច្នេះវាត្រូវការពន្ធនាគារធំជាងនេះជាបន្ទាន់។

## ភាពតានតឹងរវាងឆ្មាំ និងអ្នកទោស

ភាពចង្អៀតខ្លាំង និងការខ្វះខាតភាពចង្អៀតបិទជិតនៅក្នុងពន្ធនាគារអាចបង្កអោយមានភាពតានតឹងរវាងឆ្មាំពន្ធនាគារ និងអ្នកទោស។ យោងតាមការសម្ភាសន៍ជាមួយអ្នកទោស បានអោយដឹងថា ការខ្វះកង្ហារ ដើម្បីបក់អោយមានខ្យល់ចេញចូលបានគ្រប់គ្រាន់ និងកង្វះម្ហូបអាហារជាកត្តាជំរុញអោយមានអំពើហិង្សានានាកើតឡើង ។

## សិទ្ធិអ្នកទោសក្នុងការហាត់ប្រាណ និងដកដង្ហើមយកខ្យល់អាកាសល្អ

បញ្ហានេះមានចែងនៅក្នុងបទបញ្ញត្តិអប្បបរមារបស់អង្គការសហប្រជាជាតិ ដើម្បីប្រព្រឹត្តលើអ្នកទោសដែលបានចែងថា ប្រធានពន្ធនាគារនានា ត្រូវអនុញ្ញាតអោយអ្នកទោសហាត់ប្រាណ (មាត្រា ២១ (១) ): "អ្នកទោសណាដែលមិនធ្វើការខាងក្រៅពន្ធនាគារយ៉ាងហោចណាស់ ត្រូវ

អោយចេញហាត់ប្រាណបាន ១ ម៉ោងក្នុងពេលវេលាសមរម្យមួយនៅកណ្តាលវាល និងជារៀងរាល់ថ្ងៃប្រសិនបើអាកាសធាតុធម្មតាតាមតែអាចធ្វើទៅបាន "[៨]។

ជាទូទៅគេបានអោយអ្នកទោសចេញមកហាត់ប្រាណ និងស្រូបយកខ្យល់អាកាសខាងក្រៅបន្ទប់ឃុំឃាំងរយៈពេល ១ ម៉ោង។ ប៉ុន្តែតាមការសម្ភាសន៍ បានអោយដឹងថា បើមានអាកប្បកិរិយាប្រព្រឹត្តមិនគប្បីដោយអ្នកទោស នោះពួកឆ្មាំមិនបើកទ្វាអោយអ្នកទោសចេញក្រៅបន្ទប់ឃុំឃាំងដើម្បីហាត់ប្រាណនោះទេ។

## អនុសាសន៍

១. **ការស្វែងរកមូលនិធិបន្ថែម**។ នាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ គួរស្វះស្វែងអោយមានការបង្កើនមូលនិធិបន្ថែមពីរាជរដ្ឋាភិបាលដើម្បីធ្វើយ៉ាងណាអោយពន្ធនាគារមានទំហំធំល្មមសម្រាប់ដាក់អ្នកទោសបានសមរម្យ។

២. **ពង្រីកពន្ធនាគារខេត្តបាត់ដំបង និងកំពង់ធំ** ។ ជាអាទិភាពចម្បង នាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ គួរជួសជុល ឬស្ថាបនាពន្ធនាគារទាំងពីរសារជាថ្មីជាបន្ទាន់ ដោយពន្ធនាគារទាំងពីរនេះមានភាពចង្អៀតណែនពេក។

៣. **ទំហំពន្ធនាគារគួរសមាមាត្រនឹងចំនួនពលរដ្ឋក្នុងខេត្ត** ។ គួរផ្តល់ថវិកាអោយបានច្រើនដល់ខេត្តណាដែលមានប្រជាពលរដ្ឋច្រើន ដើម្បីអោយខេត្តមានលទ្ធភាពកសាងពន្ធនាគារអោយបានធំសមរម្យ។

៤. **សម្របសម្រួលជាមួយសង្គមស៊ីវិល**។ ក្រសួងមហាផ្ទៃ និងមន្ត្រីពន្ធនាគារនានា គួរសហការជាមួយសង្គមស៊ីវិលអោយបានល្អដើម្បីស្វែងរកវិធីផ្សេងៗ និងធនធានដើម្បីកែលំអស្ថានភាពពន្ធនាគារ។ ឧទាហរណ៍ សម្របសម្រួលដើម្បីកសាង ឬជួសជុលអគារពន្ធនាគារអោយបានធំសមរម្យជាដើម។

---

[8] បទបញ្ញត្តិអប្បបរមារបស់អង្គការសហប្រជាជាតិ ដើម្បីប្រព្រឹត្តលើអ្នកទោស នេះជាបទបញ្ញត្តិដើម្បីប្រព្រឹត្តលើអ្នកទោស។ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី១ ស្តីពីការទប់ស្កាត់បទឧក្រិដ្ឋ និងការប្រព្រឹត្តលើជនល្មើស បារព្ធធ្វើនៅទីក្រុង ហ្សឺណែវ ឆ្នាំ ១៩៥៥ ហើយបានឯកភាពដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម តាមសេចក្តីសម្រេចលេខ ៦៦៣ C (XXIV) ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៥៧ និង 2076 (LXIL) ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៥៧។

# ៤. ក្រុមជនងាយនឹងរងគ្រោះក្នុងពន្ធនាគារ

## ក. ស្ត្រី

ចំនួនអ្នកទោសជាស្ត្រីមានតិចជាងបុរសឆ្ងាយណាស់ ប៉ុន្តែក្នុងឆ្នាំ ២០០៤ នេះចំនួនស្ត្រីបានកើនឡើងគួរអោយកត់សំគាល់។ បទល្មើសដែលត្រូវបានប្រព្រឹត្តច្រើនជាងគេ គឺអំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរមនុស្សនិងគ្រឿងញៀន ចោរកម្ម ជះទឹកអាស៊ីដ និងឃាតកម្ម។

*តារាងទី ៧: ចំនួនស្ត្រីនៅក្នុងពន្ធនាគារដែលលីកាដូឃ្លាំមើល*




## ស្ថានភាពរស់នៅ

បទបញ្ញត្តិអប្បបរមារបស់អង្គការសហប្រជាជាតិដើម្បីប្រព្រឹត្តលើអ្នកទោស ត្រង់ចំណុច ៨ (ក) ចែងថា "តាមលទ្ធភាពដែលអាចធ្វើបាន បុរស និងស្ត្រីត្រូវឃុំឃាំងនៅកន្លែងដាច់ដោយឡែកពីគ្នា "។ ករណីដែលកន្លែងឃុំឃាំងទទួលឃុំឃាំងបុរសនិងស្ត្រីជាមួយគ្នា ទីតាំងសម្រាប់ឃុំឃាំងស្ត្រីទាំងមូលត្រូវអោយដាច់ពីកន្លែងឃុំឃាំងបុរស "[៩]។

យោងតាមនីតិវិធីកម្ពុជាលេខ៣ បានចែងថា ត្រូវឃុំឃាំងស្ត្រីនៅអគារដាច់ដោយឡែកពីបុរស។ ប៉ុន្តែ ជានិច្ចកាល ការឃុំឃាំងច្រើនតែធ្វើឡើងដោយរំលោភលើមាត្រានេះ។ ជាធម្មតាស្ត្រីបែរជាត្រូវបានគេដាក់ក្នុងអគារជាមួយបុរសទៅវិញ និងត្រូវបានការពារដោយឆ្មាំជាបុរសទៀតៈ

- នៅខេត្តស្វាយរៀង មានអ្នកទោសស្ត្រី ៥ នាក់ ក្នុងចំណោមអ្នកទោសសរុប ១៦៥ នាក់ ហើយស្ត្រី ៤ នាក់មានកូនតូចនៅជាមួយ។ ស្ត្រី និងកុមារត្រូវបានដាក់នៅក្នុងបន្ទប់ឃុំឃាំងជាមួយគ្នា ហើយបន្ទប់ឃុំឃាំងនោះហ៊ុំព័ទ្ធដោយបន្ទប់ឃុំឃាំងនានាដែលមានសុទ្ធតែអ្នកទោសបុរស។

[9] ឯកសារដដែលដូចនៅក្នុងទំព័រ២៥។

- នៅខេត្តបន្ទាយមានជ័យ មានអ្នកទោសស្ត្រី ២១ នាក់ ក្នុងចំណោមអ្នកទោសសរុប ៣៨០ នាក់ ដូចនៅស្វាយរៀងដែរ បន្ទប់ឃុំឃាំងស្ត្រីត្រូវហ៊ុំព័ទ្ធដោយបន្ទប់ឃុំឃាំងដែលមានសុទ្ធតែបុរស។

លើកលែងតែនៅមណ្ឌលកែប្រែទី២ (ម២) ប៉ុណ្ណោះ ដែលមានពន្ធនាគារដាច់ដោយឡែកពីគ្នារវាងស្ត្រី និងអនីតិជន។ ពន្ធនាគារផ្សេងៗទៀត គួរតែរៀបចំដាក់ស្ត្រី និងអនីតិជនដាច់ដោយឡែកដូចមណ្ឌលកែប្រែទី២ ដើម្បីអោយស្របទៅនឹងច្បាប់កម្ពុជា និងកាតព្វកិច្ចអន្តរជាតិ ជាពិសេសនៅខេត្តណាដែលមានអ្នកទោសច្រើន។

## សុខភាព និង ម្ហូបអាហារ

ការផ្តល់លទ្ធភាពអោយអ្នកទោសទទួលការព្យាបាលបានត្រឹមត្រូវនៅមានកំរិតទាបនៅឡើយ ជាពិសេសចំពោះការថែទាំកុមារ ឬម្តាយដែលមិនទាន់សម្រាលកូនហើយ ។ ជាធម្មតានៅក្នុងពន្ធ-នាគារខ្វះអនាម័យយ៉ាងខ្លាំង ហើយការហូបចុកមិនបានគ្រប់គ្រាន់ ច្រើនតែនាំអោយអ្នកទោសមានជម្ងឺ និងឆ្លងរោគផ្សេងៗ។

មានការខ្វះខាតម្ហូបអាហារ ជាពិសេសចំពោះស្ត្រីដែលទើបសម្រាលកូនថ្មីៗ ឬចំពោះស្ត្រីទាំងអស់។ ការផ្គត់ផ្គង់ម្ហូបអាហារមិនគ្រប់គ្រាន់ធ្វើអោយស្ត្រីជួបការលំបាកយ៉ាងខ្លាំង ពីព្រោះស្ត្រីពុំសូវបានទទួលម្ហូបអាហារបន្ថែមច្រើនពីគ្រួសារដូចបុរសទេ។ បច្ចុប្បន្ន **លីកាដូ**កំពុងផ្តល់នូវម្ហូបអា-ហារបន្ថែម និងសម្ភារៈចាំបាច់បន្ទាន់មួយចំនួនដល់អ្នកទោសស្ត្រី ដូចជា ត្រីងៀត អង្ករ ទឹកដោះ-គោ ផ្លែឈើ ម្សៅសាប៊ូ សំឡីអនាម័យជាដើម។ មានស្ត្រីអ្នកទោសមួយចំនួនជួយបោកគក់សម្លៀកបំពាក់អោយឆ្មាំពន្ធនាគារដើម្បីរកកម្រៃបន្ថែមសម្រាប់ទិញម្ហូមអាហារ។

## ស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ

ក្នុងខែ ធ្នូ ឆ្នាំ ២០០៤ មានស្ត្រីមានផ្ទៃពោះ ៧ នាក់នៅក្នុងពន្ធនាគារ។ ស្ត្រីមានផ្ទៃពោះគួរបានទទួលម្ហូបអាហារបន្ថែមអោយបានសមរម្យ និងត្រួតពិនិត្យសុខភាពជាប្រចាំដោយគ្រូពេទ្យដើម្បីថែរក្សាសុខភាពស្ត្រីជាម្តាយ និងទារក។

## អាចមានការរំលោភស្ត្រីក្នុងពន្ធនាគារ

ជាច្រើនឆ្នាំកន្លងមកមានរបាយការណ៍មួយចំនួន បានរាយការណ៍ថា ស្ត្រីត្រូវបានរងនូវការរំលោភលើផ្លូវភេទ និងរូបរាងកាយនៅក្នុងពន្ធនាគារ។ ប៉ុន្តែ ក្រុមអ្នកស៊ើបអង្កេតពុំបានកត់ត្រានូវករណីទាំងឡាយដែលកើតឡើងក្នុងឆ្នាំ ២០០៤ ទេ។ បញ្ហានេះមិនបាននិយាយដល់ការរំលោភលើផ្លូវភេទដែលបិទបាំងយ៉ាងជិតនៅក្នុងពន្ធនាគារផងទេ ដូច្នេះហើយទើបគ្មានរបាយការណ៍ស្តីពីបញ្ហានេះសោះ។ ការបង្អិតបង្អំ អាចជាហេតុផលមួយដែលបញ្ហានេះគ្មានរបាយការណ៍។ លទ្ធភាពនៃអំពើរំលោភផ្លូវភេទ រំលោភសេពសន្ថវៈ ឬ ការរំលោភបំពានផ្សេងៗ នៅមានកំរិតខ្ពស់នៅឡើយ។

## អនុសាសន៍

១. ត្រូវឃុំឃាំងស្ត្រីនៅក្នុងបន្ទប់ឃុំឃាំងដែលមានសុវត្ថិភាព និងឆ្ងាយពីបន្ទប់ឃុំឃាំងបុរស។

២. ត្រូវយកចិត្តទុកដាក់អោយបានហ្មត់ចត់ដើម្បីការពារអ្នកទោសស្ត្រី ពីអំពើរំលោភផ្លូវភេទ និងរំលោភសេពសន្ថវៈ។

៣. ផ្តល់សេវាសុខភាពដល់ស្ត្រីដែលជិតសម្រាលកូន និងអនុញ្ញាតអោយស្ត្រីមានលទ្ធភាពទៅសម្រាលកូននៅមន្ទីរពេទ្យ។

៤. គួរផ្តល់ម្ហូបអាហារបន្ថែម និងទឹកដល់ស្ត្រី ក៏ដូចជាផ្តល់លទ្ធភាពអោយបានពិនិត្យសុខភាព-ដោយវេជ្ជបណ្ឌិត ឬ ឆ្មប។

៥. ត្រូវអនុម័ត និងអនុវត្តគោលការណ៍សម្រាប់ស្ត្រី ។

## ខ. កុមារគ្មានទោស - កម្មវិធីផ្តល់ជំនួយដល់ស្ត្រីមានផ្ទៃពោះ និង កុមារក្នុងពន្ធនាគារ

## កុមាររស់នៅជាមួយម្តាយជាប់ឃុំឃាំង

យោងតាមនីតិវិធីពន្ធនាគារកម្ពុជាលេខ ៣៤ (មាត្រាទី ៣.២)[10] ចែងថា "កុមារអាយុក្រោម ៦ ឆ្នាំត្រូវបានអនុញ្ញាតអោយរស់នៅជាមួយម្តាយដែលជាប់ឃុំឃាំងក្នុងពន្ធនាគារ។ ក្នុងខែ ធ្នូ ឆ្នាំ ២០០៤ មានកុមារអាយុក្រោម ៦ ឆ្នាំ ចំនួន ២២ នាក់ រស់នៅជាមួយម្តាយក្នុងពន្ធនាគារ។ អ្នកស្រាវជ្រាវ បានបង្ហាយអោយឃើញថា មានកុមារ ២/៣ អាយុពី ៧ ដល់ ៩ ឆ្នាំ ដែលកំពុង

[10] នីតិវិធីពន្ធនាគារលេខ ៣៤ "ស្ត្រីមានផ្ទៃពោះ និង កុមាររស់នៅក្នុងពន្ធនាគារ" មាត្រា ៣.២ ចែងថា "កុមារអាចរស់នៅជាមួយម្តាយបានក្នុងពន្ធនាគាររហូតដល់អាយុ៦ឆ្នាំ នៅពេលដែលគេចាប់គិតថា ការធ្វើបែបនេះ ជាឧត្តមប្រយោជន៍ដល់កុមារនោះ"។

រស់នៅជាមួយម្តាយក្នុងពន្ធនាគារក្នុងខែ ធ្នូ ឆ្នាំ ២០០៤។ ម្តាយភាគច្រើនបាននិយាយថា ការទុកកូនអោយរស់នៅជាមួយពីព្រោះពួកគាត់ពុំមានថវិកា ឬសាច់ញាតិណាជួយមើលកូនអោយនៅខាងក្រៅ ។

## កង្វល់អំពីសិទ្ធិមនុស្សចំពោះកុមារដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារ

កុមារជាកូនរបស់ម្តាយជាប់ឃុំឃាំងនោះភាគច្រើនមានអាយុក្រោម ៦ ឆ្នាំ។ នេះ គឺជាអាយុដែលកុមារកំពុងលូតលាស់ទាំងផ្នែករូបរាងកាយ សង្គម និងប្រាជ្ញាស្មារតី។ តែផ្ទុយទៅវិញ អាជ្ញាធរពន្ធនាគារត្រូវផ្តល់ម្ហូបអាហារជាមូលដ្ឋានដល់កុមារទៅវិញដើម្បីស្របតាមនីតិវិធីពន្ធនាគារលេខ ៣៤ (៤.១)។[១១]

បច្ចុប្បន្ននេះ កុមាររស់នៅក្នុងពន្ធនាគារខ្វះខាតធនធាន និងអាហារបំប៉នយ៉ាងច្រើនដើម្បីអោយកុមារលូតលាស់បានសមរម្យ។ ពុំមានធនធានអ្វីសម្រាប់អប់រំកុមារឡើយ។ លើសពីនេះទៅទៀត កុមារត្រូវរងគ្រោះថ្នាក់ដល់រាងកាយទៀតផង នៅពេលដែលដាក់អោយនៅជាមួយជនល្មើសដែលធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋធន់ធ្ងរ ហើយក៏អាចរងការធ្វើបាបពីសំណាក់ធ្នាំផងដែរ។

## ការរៀបចំថ្មីនូវកម្មវិធីផ្តល់ម្ហូបអាហារដល់កុមារ និង ស្ត្រីមានពោះក្នុងពន្ធនាគារ[១២]

ក្នុងឆ្នាំ ២០០៤ កម្មវិធីផ្តល់ម្ហូបអាហារដល់កុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ បានបង្ហាញនូវភាពជោគជ័យមួយចំនួនក្នុងការបំពេញតម្រូវការជាមូលដ្ឋាន និងហ៊ឺកហ៊ឺនដល់ស្ត្រីព្រមទាំងកុមារដែលគ្មានទោសនៅក្នុងពន្ធនាគារ។ កុមារប្រមាណ ២៥ នាក់ និងស្ត្រីប្រមាណ ១០ នាក់ បានទទួលម្ហូបអាហារ និងសម្ភារៈអនាម័យពីអង្គការដៃគូរមួយចំនួន។

- ស្ថានទូតម៉ាល់តា ចូលសួរសុខទុក្ខស្ត្រី និងកុមារនៅមណ្ឌលកែប្រែទី២ រាល់កន្លះខែម្តង។ ផ្តល់សម្ភារៈដូចជា ម្ហូបអាហារ សម្ភារៈ (ចាន មុង ប្រដាប់ជូតសំអាតសម្លៀកបំពាក់ជាដើម) និងថ្នាំពេទ្យដល់ស្ត្រីមានផ្ទៃពោះ និងម្តាយដែលមានកូននៅជាមួយ។ ការផ្តល់នេះ បានបន្តធ្វើជារៀងរហូតចាប់តាំងពីឆ្នាំ ២០០២ រហូតមក។
- សង្គ្រោះកុមារអូស្ត្រាលី បានជួយផ្តល់ម្ហូបអាហារ និងសម្ភារៈផ្សេងៗទៀត រៀងរាល់សប្តាហ៍ដល់ពន្ធនាគារខេត្តកំពង់ចាម។

---

[11] ឯកសារដដែល ។

[12] ចំពោះព័ត៌មានបន្ថែមអំពីកម្មវិធីផ្តល់ជំនួយដល់កុមារនិងស្ត្រីមានផ្ទៃពោះ សូមបើកគេហទំព័រដូចខាងក្រោមៈ http://www.licadho.org/programs/adopaprison.php

- គម្រោងស្តាហ្វិស ជួយផ្គត់ផ្គង់ដល់ស្ត្រីក្នុងពេលមានផ្ទៃពោះ និងក្រោយពីសម្រាលកូនរួច នៅពន្ធនាគារក្រុងព្រះសីហនុ។ គេបានប្រើប្រាស់ជំនាញរបស់ពួកគេក្នុងការផ្តល់ជំនួយ ដោយគេមិនអោយម្សៅទឹកដោះគោទៅទារកទេ ប៉ុន្តែគេបានផ្តល់ជាម្ហូបអាហារ និងវីតាមីន ដល់ម្តាយ ដើម្បីអោយម្តាយមានទឹកដោះសម្រាប់កូនបៅគ្រប់គ្រាន់។

## អនុសាសន៍

**១.** ត្រូវដាក់កុមារ និងម្តាយអោយនៅដាច់ដោយឡែកពីបុរសដើម្បីកាត់បន្ថយការរំលោភនានា

**២.** គួរយកចិត្តទុកដាក់ដល់កុមារអោយបានត្រឹមត្រូវជាពិសេសផ្នែកសុខភាព អប់រំ និង ម្ហូបអាហារ។

**៣.** បង្កើតកម្មវិធីថែទាំ និងអប់រំកុមារ។ រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង អង្គការម្ចាស់ជំនួយ គួររិះរកវិធីផ្សេងៗ ដើម្បីអោយកុមារមានឱកាសចូលរៀនថ្នាក់មតេយ្យ និងបឋមសិក្សាក្នុងខណៈពេលដែលពួកគេកំពុងរស់នៅជាមួយម្តាយក្នុងពន្ធនាគារ។

**៤.** បង្កើនមូលនិធិបន្ថែម។ រដ្ឋាភិបាលកម្ពុជា គួរផ្តល់មូលនិធិបន្ថែមដល់ក្រុមកុមារគ្មានទោស ដែលងាយនឹងរងគ្រោះ ដោយកុមារទាំងនោះមិនគួររស់នៅក្នុងពន្ធនាគារជាកន្លែងទីមួយ សំរាប់ពួកគេឡើយ។

## គ. អ្នកទោសអនីតិជន និងយុត្តិធម៌កុមារ

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ[១៣] (CRC) ហើយតាមមាត្រា ៣១ នៃ រដ្ឋធម្មនុញ្ញ[១៤] របស់ខ្លួន រដ្ឋាភិបាលគួរតែគោរព។ ប៉ុន្តែ ការអនុវត្តជាក់ស្តែង មាត្រាជាច្រើននៃអនុ-សញ្ញាត្រូវបានរំលោភ។ អនីតិជនជាច្រើនដែលមានអាយុចន្លោះពី ១៣ និង ១៨ ឆ្នាំ ត្រូវបានគេឃុំឃាំងពីបទឧក្រិដ្ឋ។ ប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ មានការកើនឡើងនូវចំនួនអនីតិជនទាំងពិរុទ្ធជន និងទណ្ឌិត ។

*តារាងទី ៨: ចំនួនអនីតិជននៅក្នុងពន្ធនាគារដែលលីកាដូឃ្លាំមើល*

---

13 អនុសញ្ញាស្តីពីសិទ្ធិកុមារ។ សេចក្តីសម្រេចមហាសន្និបាតលេខ ៤៤/២៥ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩។

14 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ១៩៩៣។




## កម្ពុជា ត្រូវកំណត់អាយុអប្បបរមាក្នុងការទទួលខុសត្រូវនូវទោសឧក្រិដ្ឋ

ទោះបីជាកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារក៏ដោយ ក៏កិច្ចការពារដែលត្រូវផ្តល់ដល់កុមារដែលត្រូវបានគេចោទប្រកាន់ពីបទឧក្រិដ្ឋ គឺនៅទាបនៅឡើយ។ នេះមានន័យថាការចោទប្រកាន់អាចត្រូវបានចោទលើកុមារគ្រប់អាយុទាំងអស់។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងកុមារដែលមានអាយុក្រោម ១៣ ឆ្នាំ មិនត្រូវឃុំឃាំងទេ ដោយសារមានការហាមប្រាមមិនអោយឃុំឃាំងកុមារក្រោមអាយុ ១៣ ឆ្នាំ (ក្រមព្រហ្មទណ្ឌអន្តរកាល មាត្រា ១៤.៤)។[១៥]

## ការហាមប្រាមមិនអោយធ្វើទារុណកម្មត្រូវតែអនុវត្ត

មាត្រា ៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ[១៦] ហាមប្រាមមិនអោយធ្វើទារុណកម្ម ឬអំពើព្រៃផ្សៃ អមនុស្សធម៌ ឬ ធ្វើបាបបន្ទាបបន្ថោកណាមួយទៅលើកុមារឡើយ។ ប៉ុន្តែ ទារុណកម្មនៅតែកើតមាននៅពេលដែលកុមារត្រូវបានគេឃុំឃាំង។

**ការធ្វើទារុណកម្មអនីតិជន**

កាលពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៤ កុមារម្នាក់មានអាយុ ១៣ ឆ្នាំ នៅតាខ្មៅ ត្រូវបានចាប់ខ្លួន និងឃុំនៅក្នុងបន្ទប់ឃុំឃាំងរបស់នគរបាល ដោយកុមារនោះ បានកាច់សោម៉ូតូគេនៅផ្សារតាខ្មៅ។ គេបាននាំខ្លួនកុមារនោះ ទៅប៉ុស្តិ៍នគរបាលដែលនៅទីនោះនគរបាលម្នាក់បានប្រើជង្គង់អុកចំដើមទ្រូងរបស់កុមារ។ ហើយនគរបាលនោះ ក៏បានយករំពាត់មួយប៉ុន-

[15] អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា -មាត្រាទាក់ទងនឹងតុលាការ និង ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីដែលអនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល ដែលអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅឆ្នាំ ១៩៩២។

[16] មាត្រា ៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

មេដៃវាយក្បាលកុមារ ៤-៥ ដង។ ការធ្វើទារុណកម្មបែបនេះ គឺជាការបង្ខំអោយកុមារសារភាព។

## ត្រូវឃុំឃាំងកុមារដាច់ដោយឡែកពីមនុស្សចាស់

មាត្រា ៣៧ (គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ[១៧] ក៏បានចែងថាកុមារ ត្រូវដាក់អោយនៅដាច់ពីមនុស្សចាស់នៅក្នុងពន្ធនាគារ ជាពិសេស រាល់កុមារ ដែលត្រូវបានគេដកហូតសិទ្ធិសេរីភាពត្រូវដាក់អោយនៅដាច់ដោយឡែកពីមនុស្សចាស់។ គេអាចដាក់កុមារអោយនៅជាមួយមនុស្សចាស់បាន ប្រសិនបើគេយល់ថា ការដាក់នោះ អាចផ្តល់ឧត្តមប្រយោជន៍ដល់កុមារ។ ហើយគេក៏ត្រូវផ្តល់សិទ្ធិដល់កុមារ ទាំងនោះក្នុងការទាក់ទងជាមួយគ្រួសាររបស់គេជានិច្ចតាមរយៈការសរសេរលិខិតឆ្លើយឆ្លង និងការសួរសុខទុក្ខ និងជួយសង្គ្រោះក្នុងកាលទេសៈដែលចាំបាច់។" ប៉ុន្តែ កុមារនៅតែឃុំឃាំងជាមួយមនុស្សចាស់។ ការឃុំឃាំងអនីតិជនរួមជាមួយមនុស្សចាស់ក្នុង កន្លែងតែមួយគឺជាប្រការគ្រោះថ្នាក់មួយចំពោះការលូតលាស់របស់កុមារ។ ស្ថានភាពពន្ធនាគារធ្វើអោយកុមារអាចងាយទទួលរងការឆ្លងជម្ងឺ ខ្វះម្ហូបអាហារ និងអាចធ្វើអោយកុមារមានចិត្តចង់ប្រព្រឹត្តអំពើឧក្រិដ្ឋនៅពេលគេធំឡើង។

## កង្វះប្រព័ន្ធយុត្តិធម៌យុវជនដាច់ដោយឡែក

នៅកម្ពុជា ពុំទាន់មានតុលាការសម្រាប់យុវជននៅឡើយទេ ហើយពុំទាន់មានមជ្ឈមណ្ឌលឃុំឃាំងដាច់ដោយឡែកសម្រាប់កុមាររំលោភច្បាប់ផងទេ។ ពេលប្រឈមមុខនឹងតុលាការ អនីតិជនត្រូវបានគេចាត់ទុកថាប្រព្រឹត្តដូចមនុស្សចាស់ដែរ ប៉ុន្តែការកាត់ទោសទាបជាង។ ការអនុវត្តបែបនេះគួរតែកែប្រែ ដើម្បីអោយស្របតាមមាត្រា ៤០ (៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ[១៨] ដែលចែងថា "រដ្ឋជាដៃគូនានា ត្រូវប្រឹងប្រែងបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និង ស្ថាប័នដែលអនុវត្តជាពិសេសចំពោះកុមារដែលត្រូវចោទប្រកាន់ ជាប់ចោទ ឬទទួលស្គាល់ថារំលោភច្បាប់ព្រហ្មទណ្ឌ ..." ច្បាប់ថ្មី គួរបង្កើតអោយមានភាពដាច់ដោយឡែក ប៉ុន្តែត្រូវអោយស្របនឹងប្រព័ន្ធយុត្តិធម៌យុវជនដែលចាត់ទុកជាឧត្តមប្រយោជន៍ដ៏ចម្បង និងសំខាន់ដល់សិទ្ធិកុមារ។

## ការប្រព្រឹត្តក្នុងកន្លែងឃុំឃាំងនគរបាល

---

[17] មាត្រា ៣៧ (គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ មាត្រា ៤០ (៣)

[18] មាត្រា ៤០ (៣) *នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ* ។

ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចែងនៅក្នុងមាត្រា ៣៨ ថា" អនីតិជនអាយុក្រោម ១៣ ឆ្នាំ មិនអាចឃុំឃាំងលើសពី ៣៦ ម៉ោងបានទេ។ ហើយមាត្រា ៣៨ ក៏បានហាមឃាត់មិនអោយមានការឃុំឃាំងមនុស្សអាយុក្រោម ១៨ ឆ្នាំនៅកន្លែងឃុំឃាំងនគរបាលលើសពី ៤៨ ម៉ោងផងដែរ"[១៩]។

**ការឃុំឃាំងកុមារអាយុ ១០ ឆ្នាំ ខុសច្បាប់**

យោងតាមការសម្ភាសន៍របស់**លីកាដូ**នៅខេត្តកំពង់ធំ គេបានសង្ស័យកុមារាម្នាក់ថា បានលួចស្វាយចន្ទីពីក្នុងចម្ការដែលកុមារនោះធ្វើការ។ នគរបាល បានចាប់ខ្លួនកុមារនោះ ហើយយកគាត់ទៅឃុំឃាំងនៅក្នុងកន្លែងឃុំឃាំងរបស់នគរបាលនៅកំពង់ធំអស់រយៈពេល ១ ថ្ងៃ។ **លីកាដូ** បានតាមដាន និងបង្ហាញអាយុពិតរបស់កុមារដោយអោយប័ណ្ណគ្រួសាររបស់កុមារនោះទៅអាជ្ញាធរដែលបញ្ជាក់ថាកុមារនោះមានអាយុ១០ ឆ្នាំ ប៉ុណ្ណោះ។ ក្រោយមកបន្តិច អាជ្ញាធរ បានដោះលែងកុមារនោះវិញ។

## ការប្រព្រឹត្តនៅក្នុងពេលជាប់ឃុំឃាំងបណ្តោះអាសន្ន

មាត្រា ១៤ (៤) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា " អនីតិជនដែលមានអាយុក្រោម ១៣ ឆ្នាំ មិនត្រូវដាក់ក្នុងកន្លែងឃុំឃាំងបណ្តោះអាសន្ននោះទេ. អនីតិជនអាយុពី ១៣ -១៨ ឆ្នាំ មិនត្រូវយកទៅដាក់ក្នុងកន្លែងឃុំឃាំងបណ្តោះអាសន្នលើសពី១ខែបានទេ"។ មាត្រានេះ ក៏ចែងផងដែរថា រយៈពេល អាចត្រូវបានបន្ថែមដល់ទៅ ២ ខែ ប្រសិនបើអនីតិជននោះ ត្រូវបានចោទប្រកាន់ដោយបទឧក្រិដ្ឋធ្ងន់ធ្ងរ (ពុំមែនបទព្រហ្មទណ្ឌកំរិតល្មើសស្រាល)។

## មជ្ឈមណ្ឌលយុវនីតិសម្បទារចោមចៅ

អនុក្រិត្យស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងនៃមជ្ឈមណ្ឌលយុវនីតិសម្បទាសម្រាប់កុមារដែលប្រព្រឹត្តល្មើសច្បាប់ (១៩៩៤) បានគូសបញ្ជាក់ថា មជ្ឈមណ្ឌលយុវនីតិសម្បទាគឺជាមជ្ឈមណ្ឌលដែលអនុវត្តតាមមាត្រា ១ ដូចខាងក្រោម។

" *...គឺជាស្ថាប័នរដ្ឋាភិបាលចម្រុះដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងអនីតិជនមានអាយុចន្លោះពី ៧ ទៅ ១៧ ឆ្នាំ ដែលប្រព្រឹត្តខុស និងអំពើចោរកម្មនៅក្នុងប្រទេស និងមានតួនាទីក្នុងការ*

---

[19] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃរដ្ឋកម្ពុជា អនុម័តដោយរដ្ឋសភាជាតិ ក្នុងសម័យរដ្ឋកម្ពុជានៅថ្ងៃទី២៨ ខែមករា ឆ្នាំ ១៩៩៣ ហើយប្រកាសអោយប្រើដោយក្រិត្យលេខ ២១ នៃក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ។

*ស្ពារ និងអភិវឌ្ឍន៍ធនធានមនុស្សដើម្បីលើកកំពស់ក៏រិតជីវភាពរស់នៅ គំនិតប្រាជ្ញា និងសម្ភារៈ ដោយធ្វើនីតិសម្បទាកុមារទាំងនោះពីមនុស្សខ្វះវិន័យ និងអសីលធម៌ អោយក្លាយជាមនុស្សល្អ ជាពលរដ្ឋ មានវិន័យ និងមានសីលធម៌សមរម្យវិញ។*[២០]

ប៉ុន្តែ ពីមាត្រា១មក នៅមានលក្ខណៈមិនច្បាស់ថាតើ ចៅក្រមស៊ើបអង្កេតអាចកាត់ក្តី និង ផ្តន្ទាទោសអនីតិជនដាក់មជ្ឈមណ្ឌលយុវនីតិសម្បទាជំនួសពន្ធនាគារបានដែរឬទេ។

តាមមាត្រា ៧៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលបានចែងថា "បន្ទាប់ពីជនជាប់ចោទបង្ហាញ មុខលើកដំបូងភ្លាមៗ ចៅក្រមស៊ើបអង្កេតមានសិទ្ធិក្នុងការសម្រេច ត្រូវទុកជនជាប់ចោទអោយ មានសេរីភាព ឬ ឃុំខ្លួនបណ្តោះអាសន្ន។"[២១]

ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវបានកំណត់ន័យអោយបានច្បាស់លាស់ទេ ប៉ុន្តែ **លីកាដូ** បានស្នើថា មជ្ឈមណ្ឌលយុវនីតិសម្បទា គួរតែជាកន្លែងដែលចៅក្រមស៊ើបអង្កេតអាចសម្រេចអោយ ជាប់ទោសនៅក្នុងមជ្ឈមណ្ឌលនោះ ជាជាងសម្រេចទោសអោយជាប់ពន្ធនាគារ។ អនីតិជនកំពុង ស្ថិតនៅក្នុងអាយុដែលត្រូវការអប់រំ កែប្រែ ដូច្នេះគួរផ្តល់ឱកាសអោយពួកគេ បានក្លាយជាពលរដ្ឋ ល្អ។ មជ្ឈមណ្ឌលយុវនីតិសម្បទា មិនត្រឹមតែគួរជាកន្លែងជម្រៀស និងស្នាក់នៅសម្រាប់កុមារដែល អាចប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវដើរតួជាកន្លែងសម្រាប់កែប្រែទណ្ឌិតដែលជា អនីតិជនផងដែរ។ **លីកាដូ** ក៏បានស្នើអោយមានបើកមជ្ឈមណ្ឌលយុវនីតិសម្បទាផងដែរនៅតាម ខេត្តនានា។

## អនុសាសន៍

**១. នៅក្នុងច្បាប់ត្រូវមានមាត្រាចែងថា មិនត្រូវឃុំខ្លួនកុមារអាយុក្រោម ១៣ ឆ្នាំ នោះទេ។**

**២. ដាក់អនីតិជន និងមនុស្សចាស់អោយនៅដាច់ពីគ្នា។** ក្រសួងមហាផ្ទៃ គួរធានារាល់ស្ថាប័ន កែប្រែទាំងអស់ ត្រូវផ្តល់ការស្នាក់នៅដល់អនីតិជនអោយដាច់ដោយឡែកពីមនុស្សចាស់។

**៣.** ចៅក្រម គួរមានសិទ្ធិវិនិច្ឆ័យទោសអនីតិជនដាក់មជ្ឈមណ្ឌលនីតិសម្បទា។

---

[20] អនុក្រិត្យស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់មជ្ឈមណ្ឌលយុវនីតិសម្បទាសម្រាប់យុវជន ដែលប្រព្រឹត្តល្មើស (១៩៩៤)។

[21] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៧៩ ។

៤. ក្រសួងមហាផ្ទៃ គួរផ្តល់ម្ហូបអាហារ ការព្យាបាល និងការអប់រំអោយបានគ្រប់គ្រាន់ដល់អនីតិជនដែលត្រូវការការលូតលាស់ផ្នែករាងកាយ និងប្រាជ្ញាស្មារតី។

៥. ត្រូវអោយមានប្រព័ន្ធយុត្តិធម៌យុវជនសម្រាប់កុមារដែលរំលោភច្បាប់។ នេះរួមមាន ការ-បង្កើតតុលាការកុមារ ច្បាប់ដាក់ទោសសម្រាប់កុមារ និងការរិះរកវិធីដាក់ទោសដែលចាំបាច់មិនឃុំឃាំង។

## ឃ. ពិរុទ្ធជនជាប់ឃុំបណ្តោះអាសន្ន

តាមការគិតត្រួសៗ ១/៣នៃអ្នកទោសកម្ពុជាមិនទាន់ត្រូវបានកាត់ទោសនៅឡើយ។ យោងតាមតួលេខខែ ធ្នូ ឆ្នាំ ២០០៤ ៣២.២%នៃអ្នកទោសជាមនុស្សចាស់ គឺជាពិរុទ្ធជនដែលមិនទាន់កាត់ក្តីនៅឡើយ ហើយ៥០.៦%នៃអ្នកទោសដែលមានអាយុក្រោម ១៨ ឆ្នាំ ក៏ជាពិរុទ្ធជនដែលមិនទាន់កាត់ក្តីនៅឡើយដែរ។ មានការកើនឡើងនូវចំនួនពិរុទ្ធជនយ៉ាងច្រើនក្នុងឆ្នាំ ២០០៤។

*តារាង ៩: ពិរុទ្ធជនមិនទាន់កាត់ក្តីឆ្នាំ ២០០៤*




ច្បាប់ព្រហ្មទណ្ឌអន្តរកាល (មាត្រា១៤ (៤) ចែងអំពីការណែនាំក្នុងការអនុវត្តចំពោះពិរុទ្ធជនដូចខាងក្រោម :

*តារាងទី ៩: ការណែនាំអំពីការឃុំខ្លួនបណ្តោះអាសន្នក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល*

| អាយុ | រយៈពេល (ខែ) ត្រូវឃុំខ្លួន |
|---|---|
| អនីតិជនក្រោម ១៣ ឆ្នាំ | មិនអនុញ្ញាតអោយឃុំខ្លួនបណ្តោះអាសន្នរងចាំការកាត់ទោសទេ |
| អនីតិជនអាយុពី១៤ -១៧ ឆ្នាំ | ១ ខែ |
| អាយុពី១៨ឆ្នាំ ឡើងទៅ | ៤ ខែ (រហូតដល់៦ខែក្នុងកាលៈទេសៈពិសេស) |

ទោះបីជាមានការហាមប្រាមបែបនេះក៏ដោយ ក៏អ្នកស្រាវជ្រាវ**លីកាដូ** បានជួបប្រទះករណីឃុំខ្លួនលើសពីនីតិវិធីកំណត់ជាច្រើននៅតាមពន្ធនាគារនានា។ ជាសរុប ពន្ធនាគារ ៧ ក្នុងចំណោមពន្ធនាគារទាំង ១៨ (៣៨%) បានរំលោភច្បាប់នេះ។

*តារាងទី ១១: ពិរុទ្ធជនដែលត្រូវបានឃុំឃាំងលើសពីនិតិវិធីកំណត់ (ទាំងមនុស្សចាស់ និងអនីតិជន)*

| ខែ | ម១ | ម២ | PJ | កំពត | តាខ្មៅ | កំពង់ស្ពឺ | ពោធិសាត់ | សរុប |
|---|---|---|---|---|---|---|---|---|
| មករា | - | - | - | ៥ | - | - | ៨ | ១៣ |
| កុម្ភៈ | ៦០ | ៣៧ | ៣ | ១ | - | ៨ | - | ១០៩ |
| មិនា | - | - | - | ៣ | - | - | ១ | ៤ |
| មេសា | - | - | - | ៦ | - | ២៥ | - | ៣១ |
| ឧសភា | - | - | - | ១ | - | - | ១ | ២ |
| មិថុនា | ៦២ | ៤៩ | - | - | ២ | - | - | ១១៣ |
| កក្កដា | - | - | - | ២ | - | - | ២ | ៤ |
| សីហា | - | - | - | ៥ | - | ៧ | ១ | ១៣ |
| កញ្ញា | - | - | - | ៦ | - | - | - | ៦ |
| តុលា | - | - | - | - | - | ៥ | - | ៥ |
| វិច្ឆិកា | - | - | - | ៣ | - | - | - | ៣ |
| ធ្នូ | ៤៨ | ៤៤ | - | ៨ | - | ៧ | - | ១០៧ |
| សរុប | ១៧០ | ១៣០ | ៣ | ៤០ | ២ | ៥២ | ១៣ | ៤១០ |

***កំណត់សំគាល់:*** *តួលេខទាំងនេះបង្ហាញចំនួនអ្នកទោសនៅក្នុងខែនីមួយៗដែលត្រូវឃុំលើសពីនិតិវិធីកំណត់។ ក្នុងប្រអប់ដែលគ្មានលេខ គឺជាខែដែលមិនបានប្រមូលទិន្នន័យ។*

ជាទូទៅ ចំនួនពិរុទ្ធជនដែលត្រូវឃុំឃាំងលើសពីនិតិវិធីកំណត់ច្រើនជាងគេបំផុត គឺនៅមណ្ឌលកែប្រែទី១ ទី២ កំពត និងកំពង់ស្ពឺ។ មណ្ឌលកែប្រែទី១ និង ទី២ មានចំនួនពិរុទ្ធជនឃុំលើសពីនិតិវិធីកំណត់ច្រើនជាងគេ ពីព្រោះអ្នកទោសជាច្រើន ត្រូវបានគេបញ្ជូនមកពីពន្ធនាគារតាមខេត្តនានាដើម្បីរងចាំការកាត់ទោសនៅភ្នំពេញ។

## ហេតុផលដែលនាំអោយមានការឃុំឃាំងលើសពីនិតិវិធីកំណត់

បើយោងតាមមន្ត្រីពន្ធនាគារ និងតុលាការ បានផ្តល់ហេតុផលជាច្រើនទាក់ទងនឹងបញ្ហានេះដូចតទៅ :

- ចៅក្រមជំនុំជំរះនិងចៅក្រមស៊ើបអង្កេត បាននិយាយថា សំណុំរឿងច្រើនលើសលប់ ហើយមានចៅក្រមតិចតួចដែលមិនអាចបើកសវនាការករណីទាំងនោះអោយទាន់ពេលបាន។
- មន្ត្រីពន្ធនាគារ និយាយថា ពុំមានថវិកា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីដឹកពិរុទ្ធជនទៅតុលាការ។
- ចៅក្រមជំនុំជំរះ បញ្ជាក់ថា ពិរុទ្ធជនម្នាក់ៗ ត្រូវមកតុលាការ២_៣ដង (ដើម្បីអោយព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេតធ្វើបទសម្ភាសន៍ និងចូលរួមសវនាការ) ហើយតុលាការមិនអាចមានលទ្ធភាពចំណាយលើការដឹកជញ្ជូនទាំងនោះបានទេ។
- ករណីខ្លះតម្រូវអោយមានការស៊ើបអង្កេតយ៉ាងស្មុគស្មាញ ដែលត្រូវចំណាយពេលយូរ។

## អនុសាសន៍

- រាជរដ្ឋាភិបាល គួរផ្តល់ថវិកាអោយបានគ្រប់គ្រាន់ដល់ផ្នែកពន្ធនាគារដើម្បីដឹកជញ្ជូនពិរុទ្ធជនទៅតុលាការ។
- រាជរដ្ឋាភិបាល ក៏គួរតែងតាំងចៅក្រមបន្ថែមព្រមទាំងផ្តល់មធ្យោបាយចាំបាច់ ដើម្បីស៊ើបអង្កេតអោយមានប្រសិទ្ធិភាព។

# ៥. អំពើពុករលួយ

យោងតាមការសម្ភាសន៍ជាមួយអ្នកទោសជាច្រើនបានអោយដឹងថា អំពើពុករលួយនៅតែកើតមានឡើងជាបន្តបន្ទាប់នៅក្នុងជីវភាពប្រចាំថ្ងៃក្នុងពន្ធនាគារ ដែលអាចនាំអោយប៉ះពាល់ដល់ការទទួលម្ហូបអាហារ ឬ ទឹកបន្ថែម ការសួរសុខទុក្ខពីសំណាក់គ្រួសារ សាច់ញាតិ ការចេញហាត់ប្រាណ និងការដឹកជញ្ជូនទៅតុលាការជាដើម។

## ថវិកាពន្ធនាគារមិនគ្រប់គ្រាន់

អំពើពុករលួយ គឺជាលទ្ធផលនៃការផ្តល់ថវិកាមិនគ្រប់គ្រាន់ដោយក្រសួងមហាផ្ទៃ។ ចំនួនទឹកប្រាក់ ១.០០០ រៀល (០.២៥ដុល្លា) សម្រាប់អ្នកទោសម្នាក់ក្នុង១ថ្ងៃ គឺមិនអាចគ្រប់គ្រាន់ទេ។ ហើយអស់រយៈពេលជាង ១ ទសវត្សមកហើយ នៅពេលដែលទំនិញចេះតែឡើងថ្លៃក៏ដោយ ក៏ចំនួនថវិកាដែលផ្តល់អោយអ្នកទោសមិនត្រូវបានបង្កើននោះដែរ។ ក្រសួង នៅតែផ្តល់នូវប្រាក់ចំនួន ១.០០០រៀលនេះដដែលសំរាប់អ្នកទោសម្នាក់ក្នុង១ថ្ងៃ។

យោងតាមមន្ត្រីពន្ធនាគារនានា បានអោយដឹងថា ចំនួនថវិកា ១.០០០ រៀលនេះ គឺសម្រាប់ចំណាយលើម្ហូបអាហារ ការដឹកជញ្ជូន អនាម័យ អុសធ្យូង ទឹក អគ្គិសនី និងផ្នែករដ្ឋបាលផងដែរ។ តាមការពិត ចំនួននេះមិនអាចចំណាយលើថ្លៃអគ្គិសនី និងម្ហូបអាហារដែលមានសារជាតិចិញ្ចឹមអោយបានគ្រប់គ្រាន់ផងទេ។

យោងតាមនីតិវិធីពន្ធនាគារលេខ ៦ (មាត្រា ៤.១) ប្រធានពន្ធនាគារគ្រប់រូប ត្រូវធ្វើយ៉ាងណាអោយអ្នកទោសទទួលបានម្ហូបអាហារ ២ ពេលក្នុង ១ថ្ងៃ ដោយត្រូវមានបរិមាណម្ហូបអាហារអប្បបរមាដូចខាងក្រោម:

*តារាង ១២: តម្រូវការម្ហូបអាហារប្រចាំថ្ងៃសម្រាប់អ្នកទោសម្នាក់ៗ:*

| ប្រភេទម្ហូបអាហារ | បរិមាណ |
|---|---|
| អង្ករ | ៥៥០ ក្រាម |
| ត្រីសាប ឬត្រីប្រៃ ឬ សាច់ | ១៥០ ក្រាម |
| បន្លែ | ១៥០ ក្រាម |
| ប្រេងឆា | ១០ មីលីលីត្រ |
| អំបិល ឬ ទឹកត្រី | ១០ ក្រាម |
| គ្រឿងទេសផ្សេងៗសម្រាប់ស្ល | ២០ ក្រាម |

ប៉ុន្តែ ក្នុងជីវភាពជាក់ស្តែង ខាងពន្ធនាគារផ្តល់អង្ករ និងបន្លែដល់អ្នកទោសតិចតួចជាទីបំផុត។ ដោយហេតុនេះហើយ អ្នកទោសទាំងឡាយបានរងគ្រោះពីការខ្វះម្ហូបអាហារ។ អ្នកទោសមួយចំនួនដែលមានសាច់ញាតិ-គ្រួសារនៅជិត អាចទទួលបានចំណីអាហារបន្ថែមខ្លះៗ ប៉ុន្តែបញ្ហានេះមិនអាចបានដល់អ្នកទោសគ្រប់គ្នាទេ។

## ការសូកប៉ាន់ពេលគ្រួសារចូលសួរសុខទុក្ខ

យោងតាមនីតិវិធីពន្ធនាគារលេខ ៨ មាត្រា ៤.១ (ណ) ចែងថា " ការប្រមូលរបស់របរ ឬលុយកាក់ ពីអ្នកមកសួរសុខទុក្ខអ្នកទោស ដោយមន្ត្រីពន្ធនាគារ ត្រូវហាមឃាត់"។ អ្នកទោសទាំងអស់ មានសិទ្ធិទទួលជួបគ្រួសារ ឬ មិត្តភ័ក្តមកសួរសុខទុក្ខយ៉ាងហោច ១ ម៉ោងក្នុង ១ សប្តាហ៍តាមពេលវេលាកំណត់នៅក្នុងបទបញ្ជាពន្ធនាគារដែលរៀបចំដោយប្រធានពន្ធនាគារ។" [២២] គ្រួសារអ្នកទោសជាច្រើន បានប្រាប់អ្នកស្រាវជ្រាវ**លីកាដូ**ថា ពួកគេត្រូវចំណាយលុយអោយបុគ្គលិកពន្ធនាគារដើម្បីបានចូលសួរសុខទុក្ខ និងផ្តល់ម្ហូបអាហារអោយបងប្អូននៅក្នុងពន្ធនាគារ។

យោងតាមបទសម្ភាសន៍ជាមួយគ្រួសារដែលមកសួរសុខទុក្ខបងប្អូនកូនចៅរបស់គេនៅតាមពន្ធនាគារនានា បានអោយដឹងថា ការសូកប៉ាន់ ដើម្បីបានជួបអ្នកទោសមានលក្ខណៈដូចខាងក្រោមៈ

*តារាងទី ១៣: ការបង់ថវិកាចូលពន្ធនាគារ*

| | |
|---|---|
| កន្លែងត្រួតពិនិត្យដំបូង | ២.០០០ រៀល |
| ច្រកទ្វារចូលអគារពន្ធនាគារ | ២.០០០ រៀល |
| ការិយាល័យរដ្ឋបាល | ៣.០០០ រៀល |
| ក្នុងបន្ទប់ជួបគ្នា (និយាយគ្នាផ្ទាល់មាត់)<br>ក្នុងបន្ទប់ជួបគ្នា (និយាយតាមទូរស័ព្ទ ) | ៣០.០០០ រៀល<br>៥.០០០ រៀល |
| ទ្វារចូលទៅក្នុងបរិវេណពន្ធនាគារដើម្បីហុចចំណីអាហារអោយអ្នកទោស | ៣.០០០ រៀល |
| ទ្វារទី២ចូលទៅក្នុងពន្ធនាគារ | ៣.០០០ រៀល |

[22] នីតិវិធីពន្ធនាគារ លេខ ៨. ៣ (១ )(ណ )

*សំគាល់: អត្រាប្តូរប្រាក់ ១ ដុល្លា ស្មើ ៤.២០០ រៀល ។*

ជាទូទៅ គ្រួសារអ្នកទោសភាគច្រើនមានមុខរបរដូចជា អ្នករត់ម៉ូតូឌុប កសិករ អ្នកលក់ដូរតិចតួច និងកម្មកររោងចក្រជាដើម ដូច្នេះ មិនអាចមានលទ្ធភាពទៅសួរសុខទុក្ខអ្នកទោសញឹកញាប់បានទេ។ តាមមើលទៅ គ្រួសារចូលសួរសុខទុក្ខអ្នកទោសប្រហែល ១ ដង ក្នុង ១ ខែ ដោយមានអង្ករ ត្រីសាច់ បន្លែ ទឹក និងលុយកាក់បន្តិចបន្តួចសំរាប់ផ្ញើដល់អ្នកទោស។

## សំណូកដើម្បីចេញមកហាត់ប្រាណ-ត្រូវកំដៅថ្ងៃ

អ្នកទោសមានសិទ្ធិចេញមកខាងក្រៅដើម្បីហាត់ប្រាណ។ យោងតាមបទបញ្ញត្តិបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់ការប្រព្រឹត្តលើអ្នកទោសក្នុងមាត្រា ២១.ស.១: ចែងថា "អ្នកទោសទាំងអស់ដែលមិនចេញទៅធ្វើការខាងក្រៅពន្ធនាគារ យ៉ាងហោចណាស់ត្រូវអោយចេញក្រៅបន្ទប់ឃុំឃាំងដើម្បីហាត់ប្រាណក្នុងរយៈពេល ១ ម៉ោងរៀងរាល់ថ្ងៃ តាមពេលវេលាសមរម្យ និងអាកាសធាតុអំណោយផល "។ ទោះជាមានមាត្រានេះក៏ដោយ ក៏នៅមានសេចក្តីរាយការណ៍មកថា នៅក្នុងពន្ធនាគារមួយចំនួន មិនបានអោយអ្នកទោសហាត់ប្រាណ-ត្រូវកំដៅថ្ងៃ១ម៉ោងទេ ហើយបើអោយ ទាន់តែអ្នកទោសសូកផ្លាំពន្ធនាគារ ដើម្បីបានចេញក្រៅហាត់ប្រាណ។

## សំណូកពាក់ព័ន្ធនឹងតុលាការ

អ្នកទោស និងគ្រួសាររបស់ពួកគេ បានរាយការណ៍ដដែលៗថា ឆ្មាំពន្ធនាគារទារលុយ ដើម្បីដឹកជញ្ជូនអ្នកទោសទៅចូលរួមសវនាការនៅតុលាការ ឬ និយាយជាមួយចៅក្រមស៊ើបអង្កេត។ ថ្លៃដឹកជញ្ជូនពី ម១ ទៅតុលាការភ្នំពេញ គឺប្រហែលពី ៥ ទៅ ២៥ ដុល្លា អាស្រ័យទៅតាមលទ្ធភាពអ្នកទោស ។

## អនុសាសន៍

- ត្រូវផ្តល់ថវិកាបន្ថែមអោយនាយកដ្ឋានពន្ធនាគារដើម្បីបំពេញតម្រូវការជាមូលដ្ឋានរបស់អ្នកទោស។ របប ១.០០០ រៀលក្នុង ១ ថ្ងៃ សម្រាប់អ្នកទោសម្នាក់ ត្រូវបង្កើនអោយបានយ៉ាងហោចណាស់ ៤.០០០ រៀល ដើម្បីអោយល្មមតាមតម្រូវការជាមូលដ្ឋានដូចជា អាចមានម្ហូបអាហារ និងទឹកស្អាតគ្រប់គ្រាន់។ ត្រូវផ្តល់ថវិកាបន្ថែមផងដែរ ដើម្បីអោយបុគ្គលិកពន្ធនាគារទទួលប្រាក់បៀវត្សខ្ពស់ជាងមុន ហើយការធ្វើបែបនេះនឹងអាចកាត់បន្ថយការទារសំណូកពីសំណាក់បុគ្គលិកពន្ធនាគារ។

- **បើកថវិកាអោយបានទៀងទាត់។** ថវិកាក្រសួងមហាផ្ទៃដែលត្រូវបើកអោយពន្ធនាគារនានា គួរបើកអោយទាន់ពេលវេលាតាមរយៈធនាគារ ដើម្បីខាងពន្ធនាគារបើកប្រាក់បៀវត្សអោយមន្ត្រី និងថ្នាំបានទៀងទាត់ ដើម្បីកុំអោយពឹងតែលើប្រាក់សំណូកពីអ្នកទោសដើម្បីរស់។
- **អនុវត្តសវនកម្មថវិកាពន្ធនាគារដោយសវនករឯករាជ** ។ សវនកម្មអាចជួយលប់បំបាត់អំពើពុករលួយនៅក្នុងការិយាល័យហិរញ្ញវត្ថុពន្ធនាគារ។
- **ត្រួតពិនិត្យបុគ្គលិកពន្ធនាគារ។** នាយកដ្ឋានពន្ធនាគារ គួរធ្វើការត្រួតពិនិត្យបុគ្គលិកពន្ធនាគារ ជាពិសេសក្រុមថ្នាំ ដើម្បីកុំអោយថ្នាំទាំងនោះទទួល ឬ ទារសំណូកពីអ្នកទោស ឬ គ្រួសារអ្នកទោស ។
- **គួរបញ្ឈប់ការទារសំណូកសម្រាប់ការចេញហាត់ប្រាណ-ត្រូវកំដៅថ្ងៃ និងការដឹកជញ្ជូនទៅតុលាការ។** អ្នកទោសទាំងអស់មានសិទ្ធិចូលរួមក្នុងសវនាការដែលជំនុំជំរះរឿងរបស់ខ្លួន។ រដ្ឋាភិបាល គួរបង្កើនថវិកាសម្រាប់អ្នកទោសម្នាក់ៗ ដើម្បីអោយមានលទ្ធភាពចំណាយលើការដឹកជញ្ជូនទៅតុលាការបានគ្រប់គ្រាន់ផង។

# ៦. អំពើទារុណកម្ម

ទារុណកម្មនៅតែជាអំពើរំលោភមួយដ៏ធ្ងន់ធ្ងរជាទីបំផុតលើសិទ្ធិអ្នកទោសនៅក្នុងពន្ធនាគារ ដែលត្រូវបានកត់ត្រាទុកជាឯកសារដោយអ្នកស្រាវជ្រាវពន្ធនាគារ**លីកាដូ**។ តាមអនុសញ្ញាស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម បានចែងថា អ្នកទោសត្រូវបានការពារពីអំពើទារុណកម្ម អំពើព្រៃផ្សៃ អមនុស្សធម៌ ការបន្ទាបបន្ថោក ឬ ទណ្ឌកម្មនានា ។ ហើយមាត្រា ១២ (១) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលចែងថា "គ្មានពិរុទ្ធជនណាត្រូវរងអំពើព្រៃផ្សៃ អមនុស្សធម៌ ការធ្វើបាប ឬទណ្ឌកម្ម ក៏ដូចជាការវាយដំ ឬទារុណកម្មណាមួយឡើយ។"[២៣] ការស៊ើបអង្កេតរបស់**លីកាដូ** បានបង្ហាញអោយឃើញថា មានការចោទប្រកាន់ថា មានអំពើទារុណកម្មប្រព្រឹត្តលើអ្នកទោសនៅកន្លែងឃុំ-ឃាំងរបស់នគរបាល និងនៅក្នុងពន្ធនាគារនានា។

*តារាងទី ១៤: ករណីអំពើទារុណកម្មដែលរាយការណ៍ក្នុងពេលសម្ភាសន៍ បែងចែកតាមខែ និង ពិរុទ្ធជន-ទណ្ឌិត (២០០៤) ។*

| ខែ | ពិរុទ្ធជន បុរស | ទណ្ឌិតបុរស | សរុប |
|---|---|---|---|
| មករា | ២ | ២ | ៤ |
| កុម្ភៈ | ១០ | ២ | ១២ |
| មិនា | ៥ | ០ | ៥ |
| មេសា | ៤ | ១៤ | ១៨ |
| ឧសភា | ១០ | ១ | ១១ |
| មិថុនា | ៣ | ៣ | ៦ |
| កក្កដា | ៩ | ១១ | ២០ |
| សីហា | ២ | ៤ | ៦ |
| កញ្ញា | ៧ | ០ | ៧ |
| តុលា | ២ | ២ | ៤ |
| វិច្ឆិកា | ៣ | ០ | ៣ |

[23] អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និងអំពើព្រៃផ្សៃ អមនុស្សធម៌ ធ្វើបាបបន្ទាបបន្ថោក ឬទណ្ឌកម្មនានា ។ សេចក្តីសម្រេចមហាសន្និបាតលេខ ៣៩/៤៦ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤។ ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១២ (១) ។

| | | | |
|---|---|---|---|
| ផ្ទុ | ៨ | ២ | ១០ |
| សរុប | ៦៥ | ៤១ | ១០៦ |

*ពុំមានរបាយការណ៍អំពីការធ្វើទារុណកម្មលើស្ត្រីក្នុងឆ្នាំ២០០៤ទេ។*

ក្នុងបទសម្ភាសន៍ជាមួយអ្នកស្រាវជ្រាវ**លីកាដូ** របាយការណ៍អំពីករណីធ្វើទារុណកម្មទាំងអស់នៅពន្ធនាគារ ឬកន្លែងឃុំឃាំងរបស់នគរបាលត្រូវបានរាយការណ៍ដោយបុរសទាំងអស់។ ចំនួនបុរសដែលរាយការណ៍ថា បានរងអំពើទារុណកម្មមានការប្រែប្រួលពីមួយខែទៅមួយខែ ប៉ុន្តែសរុបទាំងអស់មាន ១០៥ ករណី។

*តារាងទី ១៥: ចំនួនករណីទារុណកម្មតាមពន្ធនាគារនីមួយៗ*

| ពន្ធនាគារ | កន្លែងឃុំឃាំងរបស់នគរបាល | ក្នុងពន្ធនាគារ | សរុប |
|---|---|---|---|
| PJ | ០ | ០ | ០ |
| ម១ | ៨ | ១ | ៩ |
| ម២ | ៩ | ១១ | ២០ |
| ម៣ ( តេ ៥ ) | ២ | ០ | ២ |
| ទួលស្លែង | ០ | ០ | ០ |
| តាខ្មៅ | ៤ | ០ | ៤ |
| ក្រ.ព្រ.សីហនុ | ០ | ០ | ០ |
| កំពង់ស្ពឺ | ១៤ | ០ | ១៤ |
| កំពត | ៣ | ០ | ៣ |
| កំពង់ឆ្នាំង | ៥ | ០ | ៥ |
| កំពង់ចាម | ២ | ០ | ២ |
| កំពង់ធំ | ២ | ១៦ | ១៨ |
| កោះកុង | ១ | ០ | ១ |
| ពោធិសាត់ | ៦ | ១២ | ១៨ |
| បាត់ដំបង | ០ | ០ | ០ |
| បន្ទាយមានជ័យ | ០ | ០ | ០ |
| សៀមរាប | ៩ | ១ | ១០ |
| ស្វាយរៀង | ០ | ០ | ០ |
| សរុប | ៦៥ | ៤១ | ១០៦ |

*តារាងទី ១៦: ករណីទារុណកម្មនៅក្នុងពេលឃុំឃាំងបណ្តោះអាសន្ន ដែលរាយការណ៍ក្នុងពេលសម្ភាសន៍ឆ្នាំ ១៩៩៩ - ២០០៤ ។*




តួលេខទាំងនេះបង្ហាញការថយចុះនូវចំនួនករណីទារុណកម្មនៅកន្លែងឃុំឃាំងរបស់នគរបាលពីមួយឆ្នាំទៅមួយឆ្នាំ។ ប៉ុន្តែ មានការកើនឡើងនូវអំពើទារុណកម្មក្នុងពន្ធនាគារក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលនាំអោយមានការព្រួយបារម្ភ។

គួរកត់សំគាល់ថា ការប្រមូលព័ត៌មានទាក់ទងនឹងអំពើទារុណកម្ម ជាការលំបាកខ្លាំងណាស់ ពីព្រោះជនរងគ្រោះមិនហ៊ានរាយការណ៍ទេដោយខ្លាចមានការគំរាមកំហែង អាមាស់ ឬ ការធ្វើបាបផ្លូវចិត្តផ្សេងៗទៀតជាដើម។ តាមការសម្ភាសន៍របស់អ្នកស្រាវជ្រាវ**លីកាដូ**ជាមួយនឹងអ្នកទោស ជួនកាលការសម្ភាសន៍ត្រូវធ្វើឡើងដោយមានឆ្មាំនៅក្បែរដែលស្តាប់ឮ។ ហេតុនេះហើយទើបអំពើទារុណកម្មក្នុងពន្ធនាគារនៅតែមានហើយអ្នកទោសមិនហ៊ានរាយការណ៍ទេ។

## ក. ទារុណកម្មនៅកន្លែងឃុំឃាំងនគរបាល

យោងតាមរបាយការណ៍ អំពើទារុណកម្មនៅកន្លែងឃុំឃាំងរបស់នគរបាល មាន ៦៤ ករណីក្នុងឆ្នាំ ២០០៤។ ទារុណកម្មអាចកើតឡើងយ៉ាងងាយដោយជាធម្មតាជនជាប់ចោទត្រូវឃុំឃាំងដោយពុំអាចទាក់ទងទៅខាងក្រៅបាន ដូចជា គ្រួសារបងប្អូន បុគ្គលិកសិទ្ធិមនុស្ស មេធាវី ឬគ្រូពេទ្យ ក៏មិនអាចចូលជួបបានដែរ។ ប៉ុស្តិ៍នគរបាលត្រូវបិទមិនអោយអ្នកក្រៅចូលបានទេ ដូច្នេះគេអាចមានឱកាសល្មមនឹងអាចធ្វើទារុណកម្មលើអ្នកទោសបានដោយគ្មានការត្រួតពិនិត្យបានឡើយ។

**<u>បុរសអាយុ ៥០ ឆ្នាំ ត្រូវបានធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល</u>**

បុរសពិរុទ្ធជនម្នាក់អាយុ ៥០ ឆ្នាំ ត្រូវបានគេធ្វើទារុណកម្មក្នុងកន្លែងឃុំឃាំងរបស់នគរបាលកាលពីខែសីហា ឆ្នាំ ២០០៤ នៅស្រុកស្រែអំបិល ខេត្តកោះកុង។ បុរសនោះ ត្រូវគេនាំទៅប៉ុស្តិ៍នគរបាលដោយចោទពីបទប្លន់ហើយត្រូវបានសួរចម្លើយដោយនគរបាល៥នាក់ ព្រមទាំង

មានលោកអធិការ និងអធិការរងស្រុកចូលរួមក្នុងនោះដែរ។ នគរបាលបានស្រែកគំហក និងវាយក្បាលគាត់ដោយរំពាត់ ៥ ដង។

គេបានលើកថា ហេតុផលដែលធ្វើទារុណ្ណកម្មនោះ គឺនគរបាលចង់អោយគាត់សារភាព ថា ខ្លួនគាត់ប្រាកដជាបានប្លន់មែន។

លទ្ធផលនៃការធ្វើទារុណ្ណកម្មបុរសនោះ មានការឈឺចាប់ហ៊ឹងក្នុងត្រចៀក ហើយស្តាប់មិនបានឮច្បាស់ទេ។ លើសពីនេះ គាត់ក៏ទទួលរងនូវភាពតក់ស្លុតផងដែរ។

## ខ. ទារុណ្ណកម្មក្នុងពន្ធនាគារ

ច្បាប់ព្រហ្មទណ្ឌអន្តរកាល (មាត្រា១២) ត្រង់ចំណុចចែងអំពីការប្រព្រឹត្តចំពោះពិរុទ្ធជន បានចែងថា "មិនត្រូវដាក់ខ្នោះអ្នកទោស ឬ ដាក់ក្នុងកន្លែងដាច់ដោយឡែកណាមួយឡើយ ទោះជាស្ថិតក្នុងដំណាក់កាលឃុំឃាំងបណ្តោះអាសន្ន ឬកាត់ទោសហើយក៏ដោយ"។[២៤] នេះមានន័យថា ការដាក់ខ្នោះអ្នកទោសជាទម្រង់ដាក់ទណ្ឌកម្ម មិនអាចធ្វើបានទេ។ ខ្នោះនេះ គឺសម្រាប់ប្រើជាឧបករណ៍សន្តិសុខសម្រាប់ដាក់អ្នកទោសកុំអោយរត់តែប៉ុណ្ណោះ។

នៅក្នុងសេចក្តីប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ (មាត្រា ២៥) ចែងថា "ខ្នោះដៃអាចជាឧបករណ៍តែមួយគត់ដែលត្រូវប្រើដើម្បីដាក់អ្នកទោសកុំអោយរត់ ហើយមិនត្រូវប្រើដើម្បីជាការដាក់ទោសឡើយ។"[២៥] មាត្រានោះ ក៏បានចែងផងដែរថា "ប្រធានពន្ធនាគារអាចបញ្ជាអោយដាក់ខ្នោះក្នុងករណីៈ ក) ការទប់ទល់នឹងការរត់គេច ឬ ខ) ប្រសិនបើវិធានការផ្សេងៗមិនអាចទប់ទល់ក្នុងការការពារអ្នកទោសពីការបង្ករបួសខ្លួនឯង ឬអ្នកដទៃ ឬ ពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ" ។

អ្នកទោសជាច្រើនបាននិយាយថា ពួកគេត្រូវបានដាក់ខ្នោះ២-៣ថ្ងៃ ពីព្រោះពួកគេមិនគោរពផ្នាំ ឬ វាយជាមួយអ្នកទោសផ្សេងទៀត។ នៅពន្ធនាគារកំពង់ធំ មានករណីមួយចំនួនដែលមន្ត្រីពន្ធនាគារបានដាក់ខ្នោះអ្នកទោស។ អ្នកទោសម្នាក់ត្រូវបានគេដាក់ខ្នោះអស់រយៈពេល ៤-៥ ថ្ងៃ ពីព្រោះគាត់បានរត់គេច ហើយត្រូវចាប់បានមកវិញ។ បញ្ហាផ្សេងទៀត គឺគេបានដាក់ខ្នោះអ្នកទោស ៣ នាក់ដោយសម្តែងអាកប្បកិរិយាមិនសមរម្យនៅក្នុងពន្ធនាគារ។

**ដាក់ខ្នោះជើងអស់រយៈពេល ១៦ ថ្ងៃ**

នៅថ្ងៃទី១ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង៤:៣០ រសៀល អ្នកទោសថ្មីម្នាក់ដែលត្រូវចោទប្រកាន់ពីបទរំលោភ ត្រូវបានឃុំខ្លួននៅក្នុងបន្ទប់លេខ ៥ ពន្ធនាគារខេត្តកំពង់ធំ។ ពេលគាត់

[24] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១២។

[25] ប្រកាសស្តីអំពីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)

ចូលដល់ក្នុងបន្ទប់ គេវាយគាត់ ២-៣ ដង ហើយអ្នកទោសម្នាក់ទាត់គាត់មួយជើងពីក្រោយខ្នង។ នៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង៨ យប់ មន្ត្រីពន្ធនាគារម្នាក់ និងប្រធានពន្ធនាគារចូលមកស៊ើបអង្កេតបញ្ហានេះ ហើយសម្រេចដាក់ទណ្ឌកម្មអ្នកទោសដែលទាត់អ្នកមកថ្មី ដោយដាក់ខ្នោះជើងគាត់ទាំងពីរ។

ក្នុងកំឡុងពេលដាក់ទណ្ឌកម្មនេះ អ្នកទោសនោះអាចក្រោកឈរបាន ហើយហូបចុកបានធម្មតា ប៉ុន្តែពេលដែលគាត់ត្រូវការងូតទឹក ឬទៅបន្ទប់ទឹក គាត់ត្រូវអោយគេជួយ។ ជើងរបស់គាត់បានកើតជម្ងឺស្ពឹកដោយសារការដាក់ខ្នោះនោះ។

នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ប្រធានការិយាល័យពន្ធនាគារ បាននិយាយថាគាត់បានដាក់ទណ្ឌកម្មអ្នកទោសនោះរួចហើយដូច្នេះគាត់អាចឈប់វាយទាត់ធាក់អ្នកចូលថ្មីទៀតហើយ។ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤ **លីកាដូ** បានស្នើអោយពន្ធនាគារដោះខ្នោះចេញពីអ្នកទោសនោះ ដើម្បីអោយគ្រូពេទ្យ**លីកាដូ**ពិនិត្យជម្ងឺគាត់។ ក្រោយមកនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤ គេបាន ដោះខ្នោះចេញពីជើងគាត់ទាំងស្រុង។

## ផលប៉ះពាល់ដោយអំពើទារុណ្ណកម្ម

- ទារុណ្ណកម្ម អាចបណ្តាលអោយមានផលប៉ះពាល់មកលើផ្នែករាងកាយ និងប្រាជ្ញាស្មារតីយ៉ាងយូរអង្វែងដល់ជនរងគ្រោះ។
- ទារុណ្ណកម្ម ត្រូវបានគេប្រើជាទម្រង់ទណ្ឌកម្មចំពោះអ្នកទោសណាដែលរំលោភបទញ្ញាផ្ទៃក្នុង ឬសន្តិសុខ ជាពិសេសអ្នកទោសណាមានបំណងចង់រត់គេចចេញពីពន្ធនាគារ។
- តាមការសម្ភាសន៍អ្នកទោស បានអោយដឹងថា អ្នកទោសដែលទើបមកដល់ច្រើនតែត្រូវរងការវាយដំ និងទាត់ធាក់ដើម្បីបន្ទន់ពួកគេ។
- វប្បធម៌ទារុណ្ណកម្ម អាចជំរុញអោយអ្នកទោសធ្វើទារុណ្ណកម្មអ្នកទោសដូចគ្នា ហើយជួន-កាល ឆ្មាំពន្ធនាគារ បានចាត់អោយអ្នកទោសណាម្នាក់ ធ្វើទារុណ្ណកម្មលើអ្នកទោសដូចគ្នា។

## អនុសាសន៍

- គួរអនុញ្ញាតអោយមានការសម្ភាសន៍ជាសម្ងាត់រវាងអ្នកទោស និងបុគ្គលិកសិទ្ធិមនុស្ស ។
- ពិនិត្យ និងរាយការណ៍អំពីរបួសស្នាមពេលចូលមកដល់ពន្ធនាគារ។ នីតិវិធីពន្ធនាគារលេខ ១.៣.៣ ចែងថា បុគ្គលិកពេទ្យពន្ធនាគារ ត្រូវពិនិត្យសុខភាពអ្នកទោសចូលថ្មីនៅពេលទើបចូលមកដល់ ហើយរបួសណាដែលមានស្រាប់មុនពេលចូលមកដល់ត្រូវថតរូបទុក ហើយរាយការណ៍ជូនប្រធានពន្ធនាគារ ព្រមទាំងកត់ត្រាទុកអោយបានត្រឹមត្រូវក្នុងឯកសារអ្នក-

ទោសចូល មុននឹងដាក់អ្នកទោសចូលក្នុងបន្ទប់ឃុំឃាំង។ ហើយព័ត៌មានទាំងនេះ ត្រូវផ្តល់អោយអង្គការសិទ្ធិមនុស្សផងដែរ។

- **ត្រូវហ្វឹកហ្វឺនបុគ្គលិកពន្ធនាគារ ហើយត្រូវគោរពបទបញ្ញត្តិបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តដែលមានចែងនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។**
- លប់បំបាត់ការដាក់ពិន័យដោយអ្នកទោសមកលើអ្នកទោសដូចគ្នា។ នាយកដ្ឋានពន្ធនាគារគួរណែនាំផ្នាំពន្ធនាគារអោយបញ្ឈប់ការចាត់តាំងអ្នកទោសណាមួយអោយមានអំណាចដើម្បី ដាក់ពិន័យអ្នកទោសដទៃទៀត។
- **ឆ្មាំ និងអ្នកទោសដែលធ្វើទារុណ្ឌកម្មលើអ្នកទោសដទៃ ត្រូវទទួលខុសត្រូវអំពើរបស់ខ្លួន។**
- **លប់បំបាត់ ការឃុំឃាំងដោយមិនអាចទាក់ទងមកខាងក្រៅបាន នៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល។** រាជរដ្ឋាភិបាលកម្ពុជា គួរលប់បំបាត់ការឃុំឃាំង ៤៨ ម៉ោង ដោយមិនអោយទាក់ទងមកខាងក្រៅបាននៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល ហើយអនុញ្ញាតអោយពិរុទ្ធជនជួបមេធាវី គ្រួសារ-បងប្អូន អ្នកការពារសិទ្ធិមនុស្សអោយបានឆាប់ៗតាមដែលអាចធ្វើទៅបានក្រោយពីត្រូវបានចាប់ខ្លួន។
- ធ្វើសេចក្តីព្រាងទប់ស្កាត់អំពើទារុណ្ឌកម្មនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ពាក់ព័ន្ធនឹងអង្គការក្នុងស្រុក និងអង្គការអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជា គួរដាក់បញ្ចូលការការពារអំពើទារុណ្ឌកម្មទៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី រួមមាន ការធានាអោយគ្រួសាររបស់ពិរុទ្ធជន មេធាវី និងអ្នកការពារសិទ្ធិមនុស្ស អាចចូលក្នុងកន្លែងឃុំឃាំងរបស់នគរបាលបានផង។
- បដិសេធចោលនូវចម្លើយសារភាពមិនពិត។ ដើម្បីអោយស្របទៅនឹងច្បាប់ព្រហ្មទណ្ឌកម្ពុជា និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញដែលចែងថា ចៅក្រមមិនគួរទទួលយកចម្លើយសារភាពមិនពិត ឬ ចម្លើយសារភាពទទួលបានពីកន្លែងឃុំឃាំងប៉ូលីសដែលពិរុទ្ធជនបាននិយាយថាមានការធ្វើទារុណ្ឌកម្ម។ បន្ទាប់មកទៀតចៅក្រមត្រូវតែស៊ើបអង្កេតការចោទប្រកាន់នោះ ហើយដាក់ទណ្ឌកម្មពេលដែលមានភស្តុតាងគ្រប់គ្រាន់។